00746388

**លេខ/No: D11/4//4/1**

**នៅចំពោះមុខ អង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ០៧)

ភាគីដាក់ឯកសារ: សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣ ខែ តុលា ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ សាធារណៈ / Public (ការលុប)

ស្ថានភាពចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចពីការទទួលយកបានលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ [redacted] (D11/4/3) (សំណុំរឿង ០០៣)**

---

ដាក់ដោយ៖

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក សំ សុគង់

លោកស្រី Lyma NGUYEN

**ជំនួយការផ្នែកច្បាប់៖**

លោក Andy SHEN

លោកស្រី សុខ ម៉ាលី

លោកស្រី Kate BOGAN

ផ្ញើជូន៖

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន ប្រធាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម CHUNG Chang-ho

ចៅក្រម Rowan DOWNING

ឯកសារដើម

ORIGINAL DOCUMENT/DOCUMENT ORIGINAL

ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / 12 / 2011

ម៉ោង (Time/Heure): 15 : 35

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

លេខ/No: D11/4//4/1

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Siegfried BLUNK

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew T. CAYLEY

**មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី**

លោក ហុង គឹមសួន

លោក ជួង ជូងី

លោកស្រី Silke STUDZINSKY

លោកស្រី Nushin SARKARATI

# I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ [redacted] (ម្ចាស់បណ្តឹងឧទ្ធរណ៍) បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង00៣ និង00៤ ទៅផ្នែកគាំពារជនរងគ្រោះ (VSS)[១]។ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ ផ្នែកគាំពារជនរងគ្រោះ បានបញ្ជាក់ថាពាក្យសុំរបស់[redacted] ត្រូវបាន VSS ចុះលេខ 11-VSS-00186[២]។

២. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេត (ស.ច.ស) បានប្រកាសថា កិច្ចស៊ើបសួរនៅក្នុងសំណុំរឿង00៣ បានបំពេញចប់សព្វគ្រប់ហើយ អនុលោមតាមវិធាន៦៦ (១) នៃវិធានផ្ទៃក្នុង (វិធាន)[៣]។

៣. នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១១ [redacted] បានទទួលដំណឹងស្តីពី "ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់[redacted]" ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១១ (ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំ) (D11/4/3)[៤]។ មេធាវីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ បានទទួលដំណឹងអំពីដីកាសម្រេចនេះ តាមរយៈសារអេឡិចត្រូនិកពីម្ចាស់បណ្តឹងឧទ្ធរណ៍នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១១។ សេចក្តីជូន

---

[១] នៅក្នុងសំណុំរឿង00១ និងសំណុំរឿង 00២ ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើអង្គហេតុដូចគ្នា (ពាក្យសុំលេខ D22/2073)

[២] សារអេឡិចត្រូនិកពីមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី Lyma NGUYEN ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ មានចំណងជើងថា "លិខិតទំនាក់ទំនងបន្ត - ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់[redacted] - សំណុំរឿង00៣"។

[៣] សូមមើលសេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតស្តីពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង ៣ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ http://www.eccc.gov.kh/en/articles/statement-co-investigating-judges

[៤] ក.ស.ច.ស "ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់[redacted]" ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ D11/4/3។

ដំណឹងអំពីដីកាសម្រេចនេះ ត្រូវបានផ្ញើជូនមេធាវីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍តាមរយៈសារអេឡិចត្រូនិក អ.វ.ត.ករបស់មេធាវីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១ ក៏ប៉ុន្តែមេធាវីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ទើបតែទទួលបានដំណឹងអំពីដីកាសម្រេចនេះនៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១១។

៤. ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលតំណាងដោយមេធាវីជាតិគឺលោក សំ សុគង់ និង មេធាវីអន្តរជាតិគឺលោកស្រី Lyma NGUYEN តទៅនេះសូមប្តឹងឧទ្ធរណ៍ទៅលើដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលច្រានចោលបណ្តឹងរដ្ឋប្បវេណីរបស់គាត់ក្នុងសំណុំរឿង០០៣ ដោយសម្រេចថាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនអាចទទួលយកបាន[៥]។

៥. នៅថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១១ មេធាវីអន្តរជាតិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់សំណើសុំមើលសំណុំរឿង ០០៣ និង០០៤ ទាក់ទិននឹងកូនក្តីដទៃទៀតដែលខ្លួនបានធ្វើតំណាងតាមផ្លូវច្បាប់នៅពេលនោះ[៦]។ មកត្រឹមថ្ងៃដាក់បណ្តឹងឧទ្ធរណ៍នេះ (ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១) មេធាវីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ មិនបានទទួលការឆ្លើយតបច្បាស់លាស់ណាមួយនៅឡើយទេ ទាក់ទិននឹងសំណើសុំចូលមើលសំណុំរឿងដែលពាក់ព័ន្ធនេះ[៧]។

---

[៥] វិធានផ្ទៃក្នុង២៣*ស្ទួន*(២) (វិសោធនកម្មលើកទី៧) វិធាន២៣*ស្ទួន*(២) ចែងថា៖ "នៅពេលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតំណាងដោយមេធាវី សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបានអនុវត្តតាមរយៈមេធាវីនោះ"។ លិខិតប្រគល់សិទ្ធិដោយអាណត្តិរបស់[redacted] លេខឯកសារ D11/4/3 ក្នុងសំណុំរឿង។

[៦] សារអេឡិចត្រូនិកពីមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី អ្នកស្រី Lyma NGUYEN ផ្ញើជូនក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែលមានចំណងជើងថា "សំណើសុំចូលមើលសំណុំរឿង០០៣ និង០០៤" ចុះថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១១។

[៧] មកត្រឹមថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១ កាលបរិច្ឆេទដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានទទួលការច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនទាក់ទិននឹងសំណុំរឿង០០៣ តាមរយៈសំបុត្រនៅក្នុង[redacted] ដោយមិនមានការឆ្លើយតបពេញលេញចំពោះសំណើសុំចូលមើលសំណុំរឿងទេ។

## II. ច្បាប់ និងវិធានជាធរមាន

៦. ច្បាប់ និងវិធានផ្ទៃក្នុងពាក់ព័ន្ធដែលបណ្តឹងឧទ្ធរណ៍នេះយោងរួមមាន៖ វិធានផ្ទៃក្នុង១៤, ២១, ២៣, ២៣*ស្ទួន*, ២៣*ស្ទួនបី*, ៥៣, ៥៥ និង ៧៧*ស្ទួន* (វិសោធនកម្មលើកទី៧) មាត្រា១០ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (ច្បាប់ អ.វ.ត.ក)[៨] មាត្រា៥(២) និង ២(៣) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា (កិច្ចព្រមព្រៀង)[៩] *សេចក្តីប្រកាសស្តីពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារឧក្រិដ្ឋកម្ម និងការបំពានអំណាច* (គោលការណ៍មូលដ្ឋាន)[១០] មាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) និងមាត្រា៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ (សេចក្តីណែនាំអនុវត្ត)[១១]។

## III. បទដ្ឋាននៃបណ្តឹងឧទ្ធរណ៍

---

[៨] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦)។

[៩] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣។

[១០] *សេចក្តីប្រកាសស្តីពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារឧក្រិដ្ឋកម្ម និងការបំពានអំណាច* ដែលបានអនុម័តដោយសេចក្តីសម្រេចដោយមហាសន្និបាតអង្គការសហប្រជាជាតិលេខ 40/34 ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ (តទៅនេះហៅថា "គោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ")។

[១១] ត្រូវបានអនុម័ត និងអនុញ្ញាតឲ្យចុះហត្ថលេខា ផ្តល់សច្ចាប័ន និងចូលជាភាគីដោយសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 2200A (XXI) ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមានថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦ អនុលោមទៅតាមមាត្រា៤៩ នៅគេហទំព័រ៖ http://www2.ohchr.org/english/law/ccpr.htm។

00746393



៧. វិធាន៧៧*ស្ទួន* គឺជាវិធានដាក់លាក់សម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការទទួលយករបស់ ក.ស.ច.ស[១២]។ បញ្ញត្តិនេះ បានកំណត់យ៉ាងច្បាស់លាស់អំពីបទដ្ឋាននៃបណ្តឹងឧទ្ធរណ៍។ សំអាងហេតុ ត្រូវបានកំហិតត្រឹមកំហុសឆ្គងលើអង្គហេតុ និង/ឬ លើអង្គច្បាប់ដោយ ស.ច.ស ក្នុងការចេញដីកាសម្រេច។

## IV. ការឧទ្ធលស្តាល់បណ្តឹងឧទ្ធរណ៍

៨. អនុលោមតាមវិធាន៧៧*ស្ទួន*(១) និង(២) ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ១០ ថ្ងៃ ចាប់ពីថ្ងៃទទួលដំណឹងពីដីកាសម្រេចនេះ។ ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្ញើជូនមេធាវីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍តាមរយៈសារអេឡិចត្រូនិក នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១ ហើយយោងតាមអនុស្សរណៈរបស់អង្គបុរេជំនុំជម្រះ(អ.ប.ជ) មានចំណងជើង "ការឈប់សម្រាករបស់តុលាការក្នុងអំឡុងពេលបុណ្យភ្ជុំបិណ្ឌ[១៣]" ថ្ងៃផុតកំណត់នៃការដាក់បណ្តឹងឧទ្ធរណ៍ គឺនៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១[១៤]។

---

[១២] វិធាន៧៧*ស្ទួន* ត្រូវបានអនុម័តជាលើកដំបូងនៅថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១០ និងត្រូវបានតម្កល់ទុកក្នុងវិធានផ្ទៃក្នុងដែលមានធ្វើវិសោធនកម្មលើកទី៧។ វាបានចូលជាធរមាននៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១០។

[១៣] អនុស្សរណៈរបស់អ.ប.ជ "ការឈប់សម្រាករបស់តុលាការ ក្នុងអំឡុងពេលបុណ្យភ្ជុំបិណ្ឌ" ERN 00743666 ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០១១។

[១៤] យោងតាមអនុស្សរណៈរបស់ អ.ប.ជ ភាគី ឬអ្នកដាក់ពាក្យទាំងអស់ក្នុងសំណុំរឿង 00៣ និងសំណុំរឿង 00៤ ត្រូវបានជូនដំណឹងថាការកំណត់ពេលវេលាលើការដាក់ឯកសារនឹងនៅតែអនុវត្តក្នុងអំឡុងពេលឈប់សម្រាករបស់តុលាការពីថ្ងៃទី ២៦ ដល់ ២៩ ខែ កញ្ញា។ នៅក្នុងអនុស្សរណៈនោះ ភាគី ទទួលបានការជូនដំណឹងថាផ្នែកគ្រប់គ្រងតុលាការ នឹងមិនទទួលយកការដាក់ឯកសារទៅ អ.ប.ជ ក្នុងអំឡុងពេលឈប់សម្រាកនេះទេ។ ចំពោះថ្ងៃផុតកំណត់ក្នុងការដាក់ឯកសារក្នុងអំឡុងពេលនេះ នឹងត្រូវពន្យាទៅដល់ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១។ ប្រសិនបើថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១ ត្រូវបានកំណត់ថាជាថ្ងៃទទួលយកដីកាសម្រេចស្តីពីការទទួលយកនោះ យោងតាមវិធាន ៧៧ ស្ទួន រយៈពេល១០ ថ្ងៃនៃការដាក់បណ្តឹងឧទ្ធរណ៍ ផុតកំណត់នៅថ្ងៃទី ២៤ ខែ កញ្ញា។ យោងតាមវិធាន ៣៩ (២) ដោយសារថ្ងៃផុតកំណត់ នៅ ថ្ងៃ ចុង

៩. អនុលោមតាមវិធាន៧៥នៃវិធានផ្ទៃក្នុង សេចក្ដីជូនដំណឹងស្ដីពីបណ្ដឹងឧទ្ធរណ៍ នឹងត្រូវដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ នៅថ្ងៃតែមួយ[១៥]។

១០. នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានទទួលដំណឹងពីអង្គភាពបកប្រែភាសា (ITU) ថាខ្លួនមិនមានសមត្ថភាពបកប្រែបណ្ដឹងឧទ្ធរណ៍ជាភាសាខ្មែរឱ្យទាន់ពេលវេលាដើម្បីដាក់ឯកសារនៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១ បានឡើយ[១៦]។ អាស្រ័យហេតុនេះ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី នឹងដាក់បណ្ដឹងឧទ្ធរណ៍ជាភាសាអង់គ្លេស នៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១ និងដាក់ឯកសារជាភាសាខ្មែរ នៅពេល ITU បញ្ចប់ការបកប្រែ។

១១. ដីកាសម្រេចលើការទទួលស្គាល់របស់ ស.ច.ស (D11/4/3) រួមមានសេចក្ដីសម្រេចស្ដីពីការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ អាស្រ័យហេតុនេះ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះ គួរត្រូវបានទទួលយកតាមការជាក់ស្ដែង និងត្រូវបានដាក់ទៅតាមពេលវេលាកំណត់។

## V. សេចក្ដីសន្និដ្ឋានបញ្ចប់

---

សប្ដាហ៍ កាលបរិច្ឆេទនៃការដាក់ឯកសារ ត្រូវបន្តរហូតដល់ថ្ងៃធ្វើការក្នុងសប្ដាហ៍បន្ទាប់ គឺថ្ងៃច័ន្ទ ទី ២៦ ខែ កញ្ញា ឆ្នាំ ២០១១។ យោងតាមអនុស្សរណៈរបស់អ.ប.ជ ស្ដីពីការឈប់សម្រាករបស់តុលាការក្នុងអំឡុងបុណ្យភ្ជុំបិណ្ឌ មិនមាន ការទទួលការដាក់ឯកសាររហូតដល់ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១។

[១៥] មកត្រឹមថ្ងៃសរសេរពាក្យបណ្ដឹងឧទ្ធរណ៍នេះ លេខយោងឯកសារមិនទាន់ត្រូវបានផ្ដល់ឱ្យទេ។

[១៦] ITU បានបញ្ជាក់ថាប្រសិនបើខ្លួនទទួលបានឯកសារជាភាសាអង់គ្លេសនៅថ្ងៃទី ២៦ ខែ កញ្ញានោះ ITU ប្រហែលជាអាចបញ្ចប់ការបកប្រែបណ្ដឹងឧទ្ធរណ៍នេះមិនឱ្យហួសពីថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១ ដោយហេតុថា ITU ត្រូវការរយៈពេល៦ថ្ងៃនៃថ្ងៃធ្វើការដើម្បីបកប្រែឯកសារចំនួន៣០ទំព័រ ហើយបុគ្គលិកជាតិ ឈប់សំរាកក្នុងអំឡុងពេលបុណ្យភ្ជុំបុណ្យ (ពីថ្ងៃទី ២៦ ដល់ ៣០ ខែ កញ្ញា)។ សារអេឡិចត្រូនិករបស់ ITU ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០១១ ផ្ញើជូនក្រុមអ្នកច្បាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មានចំណងជើងថា "យោង៖ តម្រូវឱ្យមានការឆ្លើយតបជាបន្ទាន់៖ សមត្ថភាពបកប្រែពីភាសាអង់គ្លេសទៅខ្មែរសម្រាប់បណ្ដឹងឧទ្ធរណ៍ស្ដីពីការទទួលយកសំណើរសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី"។

១២. ម្ចាស់បណ្ដឹងឧទ្ធរណ៍ កត់សម្គាល់ថាដីកាសម្រេចលើការទទួលស្គាល់របស់ស.ច.ស ជាប់ទាក់ទិនទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់ក្នុងសំណុំរឿង ០០៣ តែប៉ុណ្ណោះ។ វាមិនមានការលើកឡើងអំពីពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ ឡើយ។ លើសពីនេះទៅទៀត ដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានមើលឃើញថា "បានចម្លងទាំងស្រុង cut and paste" ចេញពីដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ [redacted] ដោយមាន "សំអាងហេតុ" ដូចគ្នាក្នុងការច្រានចោលបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ពួកគាត់ម្នាក់ៗ[១៧]។ ករណីទាំងពីរនេះ មានអង្គហេតុស្រដៀងគ្នា។ [redacted] និង [redacted] បានបាត់បង់សមាជិកគ្រួសារដោយសារ "ការចាប់ខ្លួន [redacted] និងការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់ ការបញ្ជូនទៅកាន់ស២១ ឬការធ្វើមនុស្សឃាត" ជាបទឧក្រិដ្ឋស្ថិតក្រោមវិសាលភាពនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣[១៨]។

១៣. មកដល់ពេលនេះ មិនមានការបញ្ជាក់បង្ហាញ ឬការទទួលខុសត្រូវពីការិយាល័យណាមួយរបស់អ.វ.ត.ក អំពីអត្តសញ្ញាណរបស់ជនដែលត្រូវចោទក្នុងសំណុំរឿង ០០៣ ឡើយ។ ទោះបីយ៉ាងណា មានមូលដ្ឋានច្បាស់លាស់ក្នុងការជឿថា [redacted] ជាបុគ្គលម្នាក់ [redacted] ដែលកំពុងស្ថិតនៅក្រោមកិច្ចស៊ើបសួរ[១៩]។

---

[១៧] ក.ស.ច.ស "ដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ [redacted]" ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១០ [sic] ឯកសារលេខ D11/2/3។

[១៨] [redacted]

[១៩] [redacted]

១៤. ពាក្យសុំនេះក៏ស្របទៅនឹងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ (**សេចក្តីណែនាំអនុវត្ត**)[២០] ផងដែរ ដែលមានចែងក្នុងមាត្រា៣.៣ ថា "ជនរងគ្រោះអាចដាក់ពាក្យសុំដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តែនៅពេលដែលសំណុំរឿងស្ថិតនៅក្នុងកិច្ចស៊ើបអង្កេត ដោយសហចៅក្រមស៊ើបអង្កេត (...)"។ ចាប់តាំងពីថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ មក ស.ច.ស បានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីរ ដែលយោងទៅដល់សំណុំរឿង ០០៣ ដែលក្នុងសំណុំរឿងនេះ ជនរងគ្រោះអាចដាក់ពាក្យសុំបាន។

១៥. ពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍បានបង្ហាញពីព្យសនកម្មដោយផ្ទាល់ដែលម្ចាស់បណ្តឹងឧទ្ធរណ៍ និងគ្រួសារ បានទទួលរងពីអំពើឧក្រិដ្ឋ ដែលមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការជឿបានថា "ជនត្រូវចោទ" (ដែលកំពុងស្ថិតក្នុងកិច្ចស៊ើបសួរ) ត្រូវទទួលខុសត្រូវ[២១]។ ពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើឡើងអនុលោមទៅតាមវិធាន២៣*ស្ទួន* ដែលចែងថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន ប្រសិនបើជនរងគ្រោះអាចបង្ហាញថាខ្លួនបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត ដោយផ្ទាល់ ពីបទឧក្រិដ្ឋណាមួយប្រឆាំងនឹងជនត្រូវចោទ។

១៦. ម្ចាស់បណ្តឹងឧទ្ធរណ៍ ស្នើសុំឲ្យមេធាវីរបស់ខ្លួនចូលមើលសំណុំរឿង០០៣ ដែលជាដំណើរការនៃជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងសូមរក្សាសិទ្ធិមានតំណាងសមស្របក្នុងបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួននៅពេលវេលាសមស្រប បន្ទាប់ពីសំណើនេះ ទទួលបានការយល់ព្រម។

---

[redacted]

[២០] សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ (០២/២០០៧ វិសោធនកម្មលើកទី១) ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨។ ។

[២១] យោងតាមសន្ទានុក្រមនៃវិធានផ្ទៃក្នុង "ជនត្រូវចោទ" *(personne mise en examen)* សំដៅលើបុគ្គលណាម្នាក់ ដែលត្រូវបានចោទប្រកាន់ចំពោះរឿងក្តីណាមួយ ក្នុងចន្លោះពេលមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រហូតដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់។

## VI. ឧទ្ធរណ៍

### ១. មូលដ្ឋានទីមួយនៃបណ្ដឹងឧទ្ធរណ៍

*ស.ច.ស បានរំលោភវិធាន២១(ក) "ដើម្បីធានាសច្ចភាពតាមផ្លូវច្បាប់ និងតម្លាភាព" នៅពេលបដិសេធ មិនទទួលយកម្ចាស់បណ្ដឹងឧទ្ធរណ៍ ដោយសំអាងថាគាត់ជា "ជនរងគ្រោះប្រយោល"*

១៧. ដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំ D11/4/3 ស្រដៀងគ្នាទៅនឹងដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំនានាពីមុនរបស់ស.ច.ស ដែលមូលដ្ឋាននៃការច្រានចោល មិនមានលក្ខណៈសមស្របឡើយ និងបង្ហាញពីសមត្ថភាព និងជំនាញនៅក្រោមបទដ្ឋានដែលបានរំពឹងទុករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិគួបនីយកម្ម។

១៨. ដោយហេតុថា [redacted][22] បញ្ជាក់ពី "ការចាប់ [redacted]" និងការឃុំឃាំង និងសម្លាប់ពួកគេនៅស២១ ដែលស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ ដូច្នេះការចោទប្រកាន់ប្រឆាំងនឹងបុគ្គលដែលត្រូវបានគេកំណត់អត្តសញ្ញាណថាជា [redacted] និង [redacted] គួរត្រូវបានពិចារណានៅក្នុងសេចក្ដីសម្រេចបដិសេធចោលនោះទេ។

១៩. ដីកាសម្រេចលើការទទួលយកពាក្យសុំ ផ្ដោតទៅលើនិយមន័យនៃពាក្យថា "ជនរងគ្រោះ" និងព្យសនកម្មដែលបណ្ដាលមកពី "ទំនាក់ទំនងហេតុផលដោយផ្ទាល់" រវាងបទឧក្រិដ្ឋរបស់ជនត្រូវចោទ និងការសម្លាប់បងប្រុសរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍។ ផ្អែកលើខ្លឹមសារដែលអាចយល់បានក្នុងដីកានេះ វាបង្ហាញថាមូលដ្ឋានក្នុងការច្រានចោលបណ្ដឹងរបស់ម្ចាស់បណ្ដឹង

[22] VSS ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ 11-VSS-00186 របស់ [redacted] សំណុំរឿង 00៣ និងសំណុំរឿង 00៤ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១។

00746398



ខន្ធវណ៌ គឺដោយសារថាគាត់មិនមានជាជនរងគ្រោះដោយ "ផ្ទាល់" ដោយសារបទឧក្រិដ្ឋ ប៉ុន្តែគាត់គ្រាន់តែជាជនរងគ្រោះ "ដោយប្រយោល"ប៉ុណ្ណោះ។ ទោះបីយ៉ាងណា មានផ្នែកខ្លះនៃដីកាសម្រេចស្តីពីការទទួលយកពាក្យសុំ ដែលលើកឡើងថា ស.ច.ស យល់ឃើញថាម្ចាស់បណ្តឹងខន្ធវណ៌ មិនមែនជា "ជនរងគ្រោះ"ទាល់តែសោះ។

២០. ដើម្បីបង្ហាញកំហុសឆ្គងរបស់ ស.ច.ស ក្នុងការបកស្រាយវិធាននោះ វាជាការចាំបាច់ដែលត្រូវបង្ហាញពីអង្គហេតុនានាដែលម្ចាស់បណ្តឹងយកជាសំអាងនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន ដែលពេលនេះបណ្តឹងខន្ធវណ៌នឹងពិនិត្យមើលចំណុចខាងក្រោម។

### ក. អង្គហេតុពាក់ព័ន្ធនឹងបងប្រុសរបស់ម្ចាស់បណ្តឹងនៅ ស២១

២១. អង្គហេតុនានាទាក់ទិននឹងការស្លាប់របស់បងប្រុសរបស់ម្ចាស់បណ្តឹងខន្ធវណ៌ឈ្មោះ [redacted] នៅស២១ ទីកន្លែងដែលគាត់ជាប់ឃុំឃាំង ទទួលរងការសួរចម្លើយ និងការធ្វើទារុណកម្ម និងនៅបឹងត្របែក ទីកន្លែងដែលគាត់ត្រូវបានដុតក្លាយជាផេះ ត្រូវបាន រៀបរាប់នៅក្នុងទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះរបស់ម្ចាស់បណ្តឹងខន្ធវណ៌ (11-VSS-00186) ដូចខាងក្រោម៖

២២. នៅខែ ធ្នូ ឆ្នាំ ១៩៧៨ បងប្រុសរបស់ម្ចាស់បណ្តឹងខន្ធវណ៌ឈ្មោះ [redacted] និង [redacted] ធ្វើដំណើរតាមទូកក្តោង [redacted] ជាពេលដែលពួកគេត្រូវបានចាប់ខ្លួននៅ [redacted]។ បុរសទាំងពីររូបនោះ ត្រូវបាននាវាចំបាំងទឹករបស់ខ្មែរក្រហមចាប់បញ្ជូនទៅគុកទួលស្លែង (ស២១) ទីកន្លែងដែលពួកគាត់ទទួលរងទារុណកម្មយ៉ាងសាហាវព្រៃផ្សៃ ដោយសារពួកគេទំនងជាត្រូវបានសង្ស័យជាថាជាភ្នាក់ងារ សេ.អ៊ី.អា (CIA) ។ ទារុណកម្ម ត្រូវបានបន្តធ្វើរហូតដល់ពេលវៀតណាមចូលធ្វើអន្តរាគមន៍/របបខ្មែរក្រហមដួលរលំ ក្នុងខែ មករា ឆ្នាំ ១៩៧៩ នៅពេលដែលបុរសទាំងពីររូបនេះ ត្រូវបានបញ្ជូនទៅបឹងត្របែក។

២៣. នៅបឹងត្របែក ប្រហែលជាមួយថ្ងៃមុនរបបខ្មែរក្រហមដួលរលំ អ្នកទាំងពីរ ត្រូវបានដុតដោយសំបកកង់រថយន្តរហូតដល់ក្លាយជាផេះ។ មិនទាន់កំណត់បានទេថាតើពួកគេត្រូវបានដុតទាំងរស់ ឬ ត្រូវបានសម្លាប់ហើយទើបយកទៅដុត។

### ខ. ម្ចាស់បណ្តឹងឧទ្ធរណ៍បានទទួលរងព្យសនកម្មដោយផ្ទាល់ និងជាលក្ខណៈបុគ្គល

២៤. ជាផលវិបាកផ្ទាល់ពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តដោយមេដឹកនាំជាន់ខ្ពស់ និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" រួមទាំង [redacted] ម្ចាស់បណ្តឹងឧទ្ធរណ៍ និងគ្រួសារ បានទទួលរង៖

[redacted]

២៥. ម្ចាស់បណ្តឹងកំណត់ថា [redacted][២៣] និងអ្នកដទៃទៀតដែលស្ថិតក្នុងប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក[២៤] ទទួលខុសត្រូវជាលក្ខណៈបុគ្គល និងជាបទព្រហ្មទណ្ឌចំពោះការចាប់ខ្លួន ការធ្វើទារុណកម្ម និងចុងក្រោយការសម្លាប់បងប្រុសគាត់ឈ្មោះ [redacted] ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមាន ការដាក់ក្នុងមន្ទីរឃុំឃាំង ការដាក់ជាទាសករ ការធ្វើទារុណកម្ម ការសម្លាប់ និងអំពើអមនុស្សធម៌ផ្សេងទៀត និងបទឧក្រិដ្ឋសង្គ្រាម រួមមាន ការបញ្ជូនដោយខុសច្បាប់ ការឃុំឃាំងដោយខុសច្បាប់ ការចាប់ជាចំណាប់ខ្មាំង ការដកហូតនូវសិទ្ធិក្នុងការទទួលបានការជំនុំ

---

[២៣] [redacted]

[២៤] មាត្រា១ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការផ្តន្ទាទោសក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣។

ជម្រះសេចក្ដីប្រកបដោយយុត្តិធម៌ ការប្រព្រឹត្តបែបអមនុស្សធម៌ ការធ្វើទារុណកម្ម ការធ្វើឲ្យរងការឈឺចាប់ខ្លាំងដោយចេតនា និងការសម្លាប់ដោយចេតនា[២៥]។

២៦. [redacted] ស្ថិតក្រោមយុត្តាធិការលើបុគ្គលរបស់ អ.វ.ត.ក ហើយត្រូវបានគេជឿថា មានតួនាទីដោយផ្ទាល់ ដោយមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលចំពោះគោលបំណងរួម និងការរៀបចំការចាប់ខ្លួន និងការសម្លាប់ជនស៊ីវិលបរទេស។ គាត់ក៏មានដើរតួនាទីផងដែរចំពោះបទឧក្រិដ្ឋនៅក្នុងប្រទេសកម្ពុជាទាំងមូល ភ្ជាប់ជាមួយតួនាទីតាមផ្លូវច្បាប់របស់ពួកមន្ត្រីរដ្ឋកម្ពុជាប្រជាធិបតេយ្យផង។ ម្យ៉ាងវិញទៀត អ្នកទាំងនោះត្រូវបានគេជឿថា ត្រូវទទួលខុសត្រូវតាមទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ[២៦]។

## គ. សេចក្តីសម្រេចរបស់ ស.ច.ស ទៅលើអង្គហេតុ និងអង្គច្បាប់

[២៥] រាល់កិច្ចស៊ើបសួរទៅក្នុងអង្គហេតុដែលបានលើកឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងជនជាប់សង្ស័យនឹងជួយក្នុងការកំណត់ពីធាតុផ្សំគតិយុត្តិនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារថា [redacted] ដែលជា [redacted] ត្រូវបានចាត់ទុកយ៉ាងច្បាស់ថាជា "ខ្មាំង" នៃរបបនេះ ជាប្រជាជនស៊ីវិលប្រឆាំងនឹងបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តយ៉ាងទូលំទូលាយ និងជាប្រព័ន្ធ។ ជាពិសេស មន្ទីរ ស២១ ដែលត្រូវបានគេស្គាល់ថាជាមន្ទីរសួរចម្លើយ [redacted] ដែលត្រូវបានចោទប្រកាន់ជាភ្នាក់ងារនេះ។ ទាក់ទិននឹងបទឧក្រិដ្ឋសង្គ្រាម ក្នុងនាមជាជនស៊ីវិល [redacted] ជាប្រភេទមនុស្សដែលត្រូវបានការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវ និងពិធីសារនានា ហើយការស៊ើបអង្កេតបន្ថែមទៀតទៅក្នុងអង្គហេតុទាំងនេះអាចជួយឲ្យបង្កើតជាធាតុផ្សំគតិយុត្តិនៃបទឧក្រិដ្ឋសង្គ្រាមដែលបានកើតឡើង។

[២៦] [redacted]

២៧. ស.ច.ស យល់ឃើញថា "អ្នកដាក់ពាក្យសុំមិនបានធ្វើការបង្ហាញទេថា ព្យសនកម្មផ្លូវចិត្តដែលខ្លួនបានលើកឡើងនោះ គឺជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់"[២៧] ក្នុងសំណុំរឿង០០៣។

២៨. [redacted]

២៩. ជាងនេះទៅទៀត វិធីសាស្ត្រនេះ មិនអាចត្រូវបានអនុវត្ត ក្នុងស្ថានភាពដែលជនរងគ្រោះផ្ទាល់ស្លាប់ដោយសារបទល្មើសឡើយ ព្រោះថាវិធីសាស្ត្រនេះមិនអនុញ្ញាតឱ្យសមាជិកគ្រួសារណាម្នាក់អាចក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីបានទេ។ ការបដិសេធរបស់ ស.ច.ស ផ្អែកលើមូលដ្ឋាននេះ បានបង្ហាញយ៉ាងច្បាស់ថា មិនមានការអនុវត្តនូវវិធាន និងគោលការណ៍ឱ្យបានត្រឹមត្រូវតាមផ្លូវច្បាប់ទេ តែមានការពាក់ព័ន្ធនឹងការគិតគូរពិចារណា និងទទួលឥទ្ធិពលនយោបាយ។

៣០. តាមរយៈការបដិសេធពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ស.ច.ស បានរំលោភទៅលើគោលការណ៍នៃភាពយុត្តិធម៌ និងជាពិសេសទៅលើគោលការណ៍តម្លាភាព និងសច្ចភាព។ ដោយផ្អែកលើ *អង្គហេតុដូចគ្នា* ទៅនឹងអង្គហេតុដែលលើកឡើងនៅក្នុងពាក្យសុំសម្រាប់សំណុំរឿង០០៣ នេះ ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីនៅសំណុំរឿង០០១[២៨] និង០០២[២៩] ពោលគឺចំពោះព្យសនកម្មផ្លូវចិត្តដោយសារការបាត់បង់បងប្រុស

---

[២៧] ក.ស.ច.ស "ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted]" ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១ ឯកសារលេខ D11/4/3 កថាខណ្ឌ៥-៩។

[២៨] រឿងក្តីប្រឆាំង កាំង ហ្គេចអ៊ាវ សំណុំរឿងលេខ ០០១/១៨ កក្កដា ២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, សាលក្រម ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារលេខ E188 កថាខណ្ឌ៦៥០។

ឈ្មោះ [redacted] ។ នៅក្នុងសំណុំរឿងទាំងពីរនេះ គាត់ត្រូវបានទទួលស្គាល់ថា ជាប្អូនប្រុសរបស់ជនរងគ្រោះផ្ទាល់។

៣១. ស.ច.ស បានទទួលស្គាល់ថា ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានទទួលយកក្នុងសំណុំរឿង០០២ ដូចខាងក្រោម៖

> "ទោះបីជាសហចៅក្រមស៊ើបអង្កេត បានទទួលយកអ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០២ ក្នុងករណី "មន្ទីរសន្តិសុខទួលស្លែង (ស២១)/ព្យសនកម្មផ្លូវចិត្ត"" ក៏ដោយ វាមិនទាន់មានភាពច្បាស់លាស់ទេថានៅក្នុងសេចក្តីសម្រេចនេះ លក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធផ្ទាល់នៃទំនាក់ទំនងហេតុ និងបច្ច័យត្រូវបានពិនិត្យស៊ីជម្រៅនៅពេលចេញសេចក្តីសម្រេចនេះ។...ទោះបីក្នុងកាលៈទេសៈបែបណាក៏ដោយទង្វើករណីនានាដែលមានក្នុងសេចក្តីសម្រេចដែលធ្វើកាលពីពេលមុននេះ មិនមានលក្ខណៈចាប់បង្ខំតម្រូវឱ្យគោរពតាមពេលវេលានោះទេ ហើយមិនអាចជាឧបសគ្គដល់សហចៅក្រមស៊ើបអង្កេត (បច្ចុប្បន្ន) ក្នុងការអនុវត្តបទប្បញ្ញត្តិនៃវិធាន ២៣ ស្ទួន (១) (ខ) ក្នុងលក្ខណៈត្រឹមត្រូវឡើយ "[៣០]។

៣២. ស.ច.ស ក៏បានទទួលស្គាល់បន្ថែមទៀតថា ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ ដូចខាងក្រោម៖

> "ទោះបីជានៅក្នុងសាលក្រមលើសំណុំរឿង០០១ (sic) អង្គជំនុំជម្រះសាលាដំបូងបានសម្រេចទទួលយកអ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ប៉ុន្តែសហចៅក្រមស៊ើបអង្កេត មិនអាចអនុវត្តតាមសំអាងហេតុ ... ដែលថាអ្នកដាក់ពាក្យសុំបានបង្ហាញថា "ព្យសនកម្មរបស់គាត់ជាផលវិបាកដោយផ្ទាល់នៃបទឧក្រិដ្ឋ ..." បានទេ"[៣១]។

---

[២៩] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាស័យដ្ឋាននៅក្រៅព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D404។

[៣០] ក.ស.ច.ស "ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted]" ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ D11/4/3 កថាខណ្ឌ៨។

[៣១] ដូចជើងទំព័រខាងលើ កថាខណ្ឌ៩។

៣៣. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី កត់សម្គាល់ថា ចៅក្រម យូ ប៊ុនឡេង គឺជាសហចៅក្រមស៊ើបអង្កេតជាតិដែលនៅក្នុងសំណុំរឿង០០២។ រូបគាត់ និងចៅក្រម Marcel LeMonde (ដែលពេលនេះជំនួសដោយចៅក្រម Siegfried BLUNK) បានកត់សម្គាល់ថា មាត្រា៣.២ នៃសេចក្តីណែនាំអនុវត្តចែងថា *"ការខូចខាតផ្លូវចិត្ត អាចគិតទាំងការស្លាប់ញាតិសន្តាន ដែលជាជនរងគ្រោះដោយសារឧក្រិដ្ឋកម្មទាំងនេះ"*។ ដើម្បីទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី ព្យសនកម្មដែលទទួលរងដោយអ្នកស្នើ មិនចាំបាច់ជាព្យសនកម្មផ្ទាល់នោះទេ ប៉ុន្តែវាត្រូវតែជាព្យសនកម្មដែលមានលក្ខណៈជាបុគ្គល"[៣២]។ ដីកាសម្រេចក្នុងសំណុំរឿង ០០២ បានលើកឡើងថា៖

> "ដើម្បីពិនិត្យថាមានព្យសនកម្មផ្លូវចិត្តជាលក្ខណៈបុគ្គល សហចៅក្រមស៊ើបអង្កេតយល់ឃើញថា៖ (ក) វាមានការសន្និតទុកជាមុននៃព្យសនកម្មខាងផ្លូវចិត្ត សម្រាប់សមាជិកសាច់ញាតិជិតស្និទ្ធរបស់ជនរងគ្រោះផ្ទាល់។ ដើម្បីអនុវត្តលក្ខណៈវិនិច្ឆ័យដូចបានកំណត់នៅក្នុងដីកានេះ សញ្ញាណនៃសាច់ញាតិជិតស្និទ្ធមិនគ្រាន់តែរាប់បញ្ចូលឪពុកម្តាយ និងកូនទេ ប៉ុន្តែថែមទាំងទំនាក់ទំនងជាប្តី/ប្រពន្ធ និងបងប្អូនបង្កើតរបស់ជនរងគ្រោះផ្ទាល់ផងដែរ។ ការសន្និតជាមុននឹងត្រូវចាត់ទុកថាមិនអាចជំទាស់/កែប្រែបាននៅក្នុងស្ថានភាពដូចខាងក្រោម៖
>
> ១. ក្នុងករណីដែលជនរងគ្រោះផ្ទាល់បានស្លាប់ ឬបាត់ខ្លួនបណ្តាលមកពីអំពើមួយដែលស្ថិតនៅក្រោមការស៊ើបសួរ។
>
> ២. ក្នុងករណីដែលជនរងគ្រោះផ្ទាល់ត្រូវបានជម្លៀសដោយបង្ខំ និងត្រូវបានបំបែកចេញពីសាច់ញាតិជិតស្និទ្ធដែលបណ្តាលមកពីអំពើណាមួយដែលស្ថិតនៅក្រោមការស៊ើបសួរ ដែលការបំបែកចេញពីគ្នានេះបង្កឲ្យសមាជិកសាច់ញាតិជិតស្និទ្ធទទួលរងនូវការឈឺចាប់ដែលឈានដល់កម្រិតទទួលយកបានថា ជាការទទួលរងព្យសនកម្មផ្លូវចិត្តជាលក្ខណៈបុគ្គល"[៣៣]។

---

[៣២] ដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាស័យដ្ឋាននៅក្រៅព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D404 កថាខណ្ឌ១៣។

[៣៣] ដូចដើងទំព័រខាងលើ កថាខណ្ឌ១៤។

៣៤. ខណៈដែល ស.ច.ស មានកំហុសឆ្គងលើអង្គច្បាប់មួយចំនួននៅក្នុងដីកាសម្រេចលើការទទួលយកពាក្យសុំលេខ D11/4/3 កំហុសឆ្គងដោយផ្ទាល់គឺភាពមិនស៊ីសង្វាក់គ្នានៃការបកស្រាយផ្លូវច្បាប់ចំពោះវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តដែលពាក់ព័ន្ធ ដែលបង្កើតបានជាការរំលោភយ៉ាងច្បាស់ទៅលើវិធាន២១(១)(គ) ដែលធានាតម្លាភាព និងសច្ចភាពក្នុងដំណើរការនីតិវិធី។

៣៥. ចៅក្រម **យូ ប៊ុនឡេង** ជាចៅក្រមស៊ើបអង្កេតដដែលដែលបានចេញដីកាសម្រេចស្តីពីការទទួលយកពាក្យសុំក្នុងសំណុំរឿង០០២។ នៅក្នុងករណីរបស់គាត់ ចៅក្រមរូបនេះខកខានមិនបានអនុវត្ត *ឱ្យបានស៊ីសង្វាក់គ្នា* នូវការបកស្រាយសេចក្តីណែនាំអនុវត្ត និងវិធានផ្ទៃក្នុងដដែល ដែលគាត់បានធ្វើក្នុងសំណុំរឿង០០២។

៣៦. គោលការណ៍សច្ចភាពតាមផ្លូវច្បាប់ តាមន័យចង្អៀត *(sensu stricto)* មានន័យថា មនុស្សគ្រប់រូបមានសិទ្ធិរំពឹងថាទទួលបានលទ្ធផលមួយតាមផ្លូវតុលាការដែលអាចព្យាករណ៍បាន និងបានការការពារពីការសម្រេចដែលមិនត្រឹមត្រូវ។ ការបដិសេធចោលដោយមិនសមហេតុផលចំពោះអ្នកដាក់ពាក្យសុំនៅក្នុងដីកាដែលរងការជំទាស់នេះ រំលោភលើគោលការណ៍យុត្តិធម៌ តម្លាភាព ការទទួលខុសត្រូវ និងសច្ចភាពនៃវិធាន២១។

៣៧. ដីកាសម្រេចរបស់ស.ច.ស គួរត្រូវបានច្រានចោល ដោយសារតែដីកាសម្រេចបាននោះរំលោភវិធាន២១ នៃវិធានផ្ទៃក្នុង និងគោលការណ៍នីតិរដ្ឋ ដែលថាប្រសិនបើអនុវត្តឱ្យបានស៊ីសង្វាក់គ្នា ចំពោះអង្គហេតុ*ដដែល* និងអង្គច្បាប់*ដដែល* នោះនឹងនាំឱ្យមាន*លទ្ធផលដដែល* មិនខាន[៣៤]។

## ២. មូលដ្ឋាននីតិវិធីនៃបណ្តឹងឧទ្ធរណ៍

[៣៤] អង្គការសហប្រជាជាតិ "ដូចម្តេចដែលហៅថានីតិរដ្ឋ" នៅក្នុង៖ http://www.unrol.org/article.aspx?article_id=3

## *ស.ច.ស បានរំលោភវិធាន២៣ស្ទួន(១)(ខ) និងមាត្រា៣.២(គ) នៃសេចក្ដីណែនាំអនុវត្តស្ដីពីការចូលរួមរបស់ជនរងគ្រោះ*

### ក. ព្យសនកម្មជាលក្ខណៈបុគ្គលជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ

៣៨. នៅក្នុងការបដិសេធសម្រាប់សំណុំរឿង០០៣ ស.ច.ស បានសម្រេចថា "អ្នកដាក់ពាក្យសុំមិនបានធ្វើការបង្ហាញទេថា ព្យសនកម្មផ្លូវចិត្តដែលខ្លួនបានលើកឡើងនោះ គឺជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់" ។ ស.ច.ស បានសម្រេចបន្តទៀតថា៖

> "វិធាន២៣*ស្ទួន*(១)(ខ)តម្រូវថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបង្ហាញថា គាត់បានទទួលរងព្យសនកម្មជាផលវិបាកដោយផ្ទាល់នៃបទឧក្រិដ្ឋប្រឆាំងនឹងជនត្រូវចោទ។ បើតាមការប្រើប្រាស់អត្ថន័យជាភាសាអង់គ្លេស ពាក្យថា "direct" ("ដោយផ្ទាល់") នៅក្នុងបរិបទនេះមានន័យថា បទឧក្រិដ្ឋនោះបណ្ដាលឲ្យមានព្យសនកម្មដោយពុំមានទំនាក់ទំនងដោយផ្ទាល់រវាងហេតុ និងបច្ច័យទេ។ ទោះជាយ៉ាងណាក្ដី នៅក្នុងករណីនេះ ទំនាក់ទំនងផ្ទាល់ដែលបណ្ដាលឱ្យមានព្យសនកម្មផ្លូវចិត្តដល់អ្នកដាក់ពាក្យសុំគឺជាការស្លាប់បងប្រុសរបស់គាត់។ បើគ្មានទំនាក់ទំនងនេះទេ ព្យសនកម្មរបស់គាត់មិនអាចបណ្ដាលមកពីបទឧក្រិដ្ឋនេះបានឡើយ។ ចំណងហេតុ និងបច្ច័យនៅក្នុងករណីនេះជាទម្រង់សង្ខេបគឺជា៖ បទឧក្រិដ្ឋរបស់ជនត្រូវចោទ ការស្លាប់បងប្រុសគាត់ និងព្យសនកម្មរបស់អ្នកដាក់ពាក្យសុំ"[៣៥]។

៣៩. ទោះបី ស.ច.ស ទទួលស្គាល់ម្ចាស់បណ្ដឹងឧទ្ធរណ៍ជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ក៏ដោយ ក៏ ស.ច.ស យល់ឃើញថាសេចក្ដីសម្រេចលើការទទួលយកពាក្យសុំក្នុងសំណុំរឿង០០២ ជាការមិនត្រឹមត្រូវ ដោយសារការសម្រេចនោះ "មិនបានធ្វើការពន្យល់ ឬពិនិត្យមើលលក្ខខណ្ឌតម្រូវអំពីពាក្យថា "ផ្ទាល់" ហើយ "ហេតុផលដែលផ្ដល់មកនេះ [sic] មិនពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវនៃភាពដោយផ្ទាល់នៃហេតុ និងបច្ច័យនោះឡើយ"[៣៦]។ ស.ច.ស

---

[៣៥] ក.ស.ច.ស "ដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ [redacted]" ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ D11/4/3 កថាខណ្ឌ៥។

[៣៦] ដូចជើងទំព័រខាងលើ កថាខណ្ឌ៨។

បានបន្តថា "ទោះបីក្នុងកាលៈទេសៈបែបណាក៏ដោយ ទឡ្ហីករណ៍ដែលមានក្នុងសេចក្តីសម្រេច ដែលធ្វើកាលពីមុននោះ មិនមានលក្ខណៈចាប់បង្ខំតម្រូវឱ្យគោរពតាមនោះទេ..."[៣៧]។

៤០. ពាក់ព័ន្ធនឹងការទទួលយកម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង០០១ វិញ ស.ច.ស ទំនងជា លើកជាទឡ្ហីករណ៍ ថាសាលក្រមលើសំណុំរឿង០០១ បានលើកយោងទៅក្រមនីតិវិធីព្រហ្ម ទណ្ឌបារាំង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៦៤ ដែលថាអ្នកដែលបាន "រងព្យសនកម្ម ផ្ទាល់ខ្លួន ដោយសារបទល្មើសនោះដោយផ្ទាល់" អាចដាក់ពាក្យបណ្តឹង ដែលការយោងនេះមិន "មានលក្ខណៈគ្រប់គ្រាន់ទេ" ដោយសារ "មិនបានពន្យល់ពីលក្ខខណ្ឌតម្រូវនៃពាក្យថា "ដោយ ផ្ទាល់"[៣៨]។

៤១. ទឡ្ហីករណ៍របស់ ស.ច.ស មានភាពចន្លោះប្រហោង ដោយសារតាមវិធីណាក៏ដោយ កង្វះ និយមន័យនៃពាក្យថា "ដោយផ្ទាល់" នៅក្នុងបញ្ញត្តិច្បាប់ មិនអាចឱ្យមានការចេញសេចក្តី សម្រេចដែលមានកំហុសឆ្គងនោះទេ។ ការពិត គឺចៅក្រមជាអ្នកសម្រេចលើការបកស្រាយ បញ្ញត្តិនានា។

៤២. វិធាន២៣*ស្ទួន*(១)(ខ) ចែងថា ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួល យកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវ "បង្ហាញជាលទ្ធផលដោយ ផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើ ជនត្រូវចោទ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬផ្លូវ ចិត្ត"។ ហេតុនេះ ធាតុផ្សំបីសំខាន់ដែលត្រូវបង្ហាញ និងបញ្ជាក់ដោយម្ចាស់បណ្តឹងឧទ្ធរណ៍រួម មាន៖ (១) អត្ថិភាពនៃព្យសនកម្ម (២) ជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ និង (៣) ព្យសនកម្ម ជាលក្ខណៈផ្ទាល់ខ្លួន។

---

[៣៧] ដូចជើងទំព័រខាងលើ។

[៣៨] ដូចជើងទំព័រខាងលើ កថាខណ្ឌ៩។

៤៣. ការពិតដែលគ្មានការសង្ស័យនោះគឺថា ម្ចាស់បណ្តឹងឧទ្ធរណ៍បានបង្ហាញពីព្យសនកម្មផ្ទាល់ខ្លួន ដែលគាត់ទទួលរងជាលទ្ធផលនៃការបាត់បង់បងប្រុសឈ្មោះ [redacted][៣៩]។ វិធាន២៣*ស្ទួន*(១)(ខ) តម្រូវឲ្យមានលក្ខណៈវិនិច្ឆ័យដើម្បីអាចទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីបានថា ព្យសនកម្មដែលជនរងគ្រោះបានរងជា "លទ្ធផល*ដោយផ្ទាល់*ពីបទល្មើសនោះ"។ ទោះជាយ៉ាងណាក្តី និយមន័យនេះមិនបានឆ្លុះបញ្ចាំងនូវនិយមន័យនៃពាក្យថា "ជនរងគ្រោះ" នៅក្នុងសទ្ទានុក្រមនៃវិធានផ្ទៃក្នុងទេ ដែលចែងថា "ជនរងគ្រោះសំដៅទៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលរងព្យសនកម្ម ដោយសារអំពើឧក្រិដ្ឋកម្ម *ដែលស្ថិតនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ*"[៤០] (គូសបញ្ជាក់បន្ថែម)។

៤៤. ក្នុងការកំណត់លក្ខខណ្ឌតម្រូវដែលថា ព្យសនកម្មត្រូវតែជាលទ្ធផល*ដោយផ្ទាល់* ពីបទឧក្រិដ្ឋ/បទល្មើស អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ព្យសនកម្មអាចត្រូវបានទទួលរងដោយ "ជនរងគ្រោះផ្ទាល់ និងសាច់ញាតិជិតស្និទ្ធ"[៤១]។ អង្គជំនុំជម្រះនេះបានបន្តទៀតថា "*នៅក្នុងករណីលើកលែងមួយចំនួន* ការខូចខាតដែលចោទប្រកាន់ដោយសមាជិកនៃគ្រួសារសាច់ឆ្ងាយរបស់ជនរងគ្រោះ *ក៏អាច*ចាត់ទុកថាជាផលវិបាកនៃបទល្មើស"[៤២](គូសបញ្ជាក់បន្ថែម)។ ជាលក្ខខណ្ឌចាំបាច់ អង្គជំនុំជម្រះសាលាដំបូងតម្រូវថា "អ្នកដាក់ពាក្យសុំមានលទ្ធភាពបង្ហាញភស្តុតាងទាំង*ភាពជាសាច់ញាតិ* និង*អត្ថិភាពនៃកាលៈទេសៈដែលបណ្តាលឱ្យមានចំណងពិសេសនៃសេចក្តីស្រឡាញ់* ឬអ្នកនៅក្នុងបន្ទុករបស់អ្នកដែលទទួលមរណភាព"[៤៣]។

---

[៣៩] សូមមើលទំព័រទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះលេខ 11-VSS-00186

[៤០] សទ្ទានុក្រមនៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៧)។

[៤១] រឿងក្តីប្រឆាំង កាំង ហ្កេចអ៊ាវ សំណុំរឿងលេខ ០០១/១៨ កក្កដា ២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, សាលក្រម ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារលេខ E188 កថាខណ្ឌ៦៤៨។

[៤២] ដូចជើងទំព័រខាងលើ កថាខណ្ឌ៦៤៣។

[៤៣] ដូចជើងទំព័រខាងលើ កថាខណ្ឌ៦៤៣។

៤៥. នៅក្នុងសំណុំរឿង០០១ ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី ផ្អែកលើការបកស្រាយតាមន័យចង្អៀតនេះ ដែលលក្ខខណ្ឌតម្រូវអប្បរមានោះគឺត្រូវបង្ហាញថា "ព្យសនកម្មទទួលរងពីផលវិបាកដោយផ្ទាល់"[៤៤]។

**ខ. មាត្រា៣.២( គ) នៃសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ**

៤៦. ការបកស្រាយដែលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានប្រកាន់យក ត្រូវបានគាំទ្រយ៉ាងច្បាស់ដោយសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ ដែលចែងថា៖

> "ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ដើម្បីអាចឱ្យចាត់ទុកថាជាជនរងគ្រោះ ដែលស្ថិតនៅក្នុងគោលបំណងរបស់ អ.វ.ត.ក៖
>
> ក. អ្នកប្តឹងត្រូវជារូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានទទួលរងព្យសនកម្ម ដោយសារឧក្រិដ្ឋកម្មណាមួយស្ថិតនៅក្នុងយុត្តាធិការនៃ អ.វ.ត.ក។
>
> ខ. ដើម្បីត្រូវបានកំណត់ថាបានរងព្យសនកម្ម អ្នកប្តឹងត្រូវបង្ហាញ៖
> - ការខូចខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត និង
> - ជាផលលំបាកដោយផ្ទាល់ពីឧក្រិដ្ឋកម្មនោះ ជាព្យសនកម្មដោយផ្ទាល់ខ្លួន និងបានកើតមានពិតប្រាកដមកទល់ពេលបច្ចុប្បន្ន។"

**គ. ព្យសនកម្មផ្លូវចិត្តអាចរួមទាំងការស្លាប់របស់សាច់ញាតិដែលជាជនរងគ្រោះនៃបទឧក្រិដ្ឋបែបនេះ (គូសបញ្ជាក់បន្ថែម)**

៤៧. សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះបានបញ្ចូល*យ៉ាងច្បាស់*នូវការស្លាប់របស់សាច់ញាតិជិតដែលជាជនរងគ្រោះ (ផ្ទាល់)។ ការបដិសេធមិនទទួលយកម្ចាស់បណ្តឹង

---

[៤៤] វិធីសាស្ត្របែបចង្អៀតនៅក្នុងសំណុំរឿង០០១ ត្រូវបានដើមបណ្តឹងរដ្ឋប្បវេណីប្តឹងឧទ្ធរណ៍ទៅអង្គជំនុំជម្រះតុលាការកំពូល ទាក់ទិននឹងការមិនទទួលយកពាក្យសុំរបស់ខ្លួន ហើយអង្គជំនុំជម្រះនេះកំពុងធ្វើសេចក្តីសម្រេច។

00746410



ឧទ្ធរណ៍ ដោយផ្អែកលើសំអាងហេតុថា គាត់មិនមែនជាជនរងគ្រោះផ្ទាល់ ស.ច.ស បាន រំលោភ និង/ឬ បានបកស្រាយដោយភ័ន្តច្រឡំទៅលើសេចក្ដីណែនាំអនុវត្តដែលមានជាធរមាន។

៤៨. ដើម្បីឱ្យមានភាពពេញលេញ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សូមយោងទៅដល់យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ ដែលផ្ដល់នូវការណែនាំលើសពីអ្វីដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ទៅទៀត។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC បានទទួលស្គាល់ទាំងជនរងគ្រោះផ្ទាល់ និងប្រយោល ហើយបានសម្រេចថា៖

> "បញ្ហាដែលត្រូវសម្រេចនោះគឺថាតើព្យសនកម្មដែលទទួលរងនោះមានលក្ខណៈជាបុគ្គលផ្ទាល់ឬទេ។ ប្រសិនបើវាមានលក្ខណៈជាបុគ្គលនោះ គេអាចភ្ជាប់ព្យសនកម្មនោះជាមួយជនរងគ្រោះផ្ទាល់ និងប្រយោលបាន។ ថាតើបុគ្គលនោះបានទទួលរង ឬមិនបានទទួលរងព្យសនកម្មជាលទ្ធផលនៃបទឧក្រិដ្ឋដែលស្ថិតក្នុងយុត្តាធិការនៃតុលាការនោះក៏ដោយ ហើយដូច្នេះគាត់ជាជនរងគ្រោះនៅចំពោះមុខតុលាការ ត្រូវតែត្រូវសម្រេចដោយពិនិត្យមើលទៅលើកាលៈទេសៈពិសេសផ្សេងៗ"។[៨៥] (គូសបញ្ជាក់បន្ថែម)

៤៩. ជាងនេះទៅទៀត វិធាន៨៥(ក) នៃវិធាននីតិវិធី និងភ័ស្តុតាង (**RPE**) នៃតុលាការ ICC *មិន*តម្រូវថា ព្យសនកម្មត្រូវតែជាផលវិបាក "ដោយផ្ទាល់" ទេ[៨៦]។ ចំណុចនេះស្របទៅនឹងនិយមន័យនៃពាក្យថា "ជនរងគ្រោះ" នៅក្នុងសន្ទានុក្រមវិធានក្នុង ដែលដូចគ្នាបេះបិទនឹង RPE។ ជាលក្ខណៈអន្តរជាតិ ព្យសនកម្មដែលទទួលរងមិនចាំបាច់ត្រូវតែជា "លទ្ធផលដោយផ្ទាល់នៃការប្រព្រឹត្តបទឧក្រិដ្ឋដែលស្ថិតក្នុងយុត្តាធិការ" ទេ តែត្រូវតែជាលក្ខណៈបុគ្គល។

---

[៨៥] ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo សំណុំរឿងលេខ ICC-01/04-01/06-1432 ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៨ កថាខណ្ឌ៣២។ គូសបញ្ជាក់បន្ថែម។

[៨៦] វិធាន៨៥(ក) RPE នៃចែងថា៖ ""ជនរងគ្រោះ" មានន័យថាជារូបវន្តបុគ្គលដែលបានទទួលរងព្យសនកម្មជាលទ្ធផលនៃការប្រព្រឹត្តបទឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ"។

៩០. តុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង (**IACHR**) បានផ្តល់សំណងដល់ក្រុមគ្រួសារសាច់ញាតិ និងដៃគូរបស់ជនរងគ្រោះ មិនត្រឹមតែក្នុងករណីនៃការបាត់ខ្លួនប៉ុណ្ណោះទេ[៤៧] តែទាំងក្នុងករណីសម្លាប់[៤៨] និងក្នុងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដែលជនរងគ្រោះមិនបានស្លាប់ ឬបាត់ខ្លួន[៤៩] ផងដែរ។ តុលាការ IACHR យល់ឃើញថា គេអាចសន្និដ្ឋានបានថា ឪពុកម្តាយ កូនចៅ បងប្អូនបង្កើត និងដៃគូរបស់ជនរងគ្រោះផ្ទាល់ បានបំពេញតាមលក្ខខណ្ឌតម្រូវទាំងនេះ ហើយអ្នកទាំងនោះត្រូវតែត្រូវបានចាត់ទុកថាជាជនរងគ្រោះប្រយោល[៥០]។

---

[៤៧] រឿងក្តី *Velásquez Rodríguez តទល់នឹង ប្រទេសហុងឌូរ៉ាស (ការជួសជុលព្យសនកម្ម)* សាលក្រមថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៨៩ ស៊េរី គ លេខ៧ កថាខណ្ឌ៥០-៥២; សំណុំរឿង *Garrido និង Baigorria តទល់នឹង ប្រទេសអាហ្សង់ទីន (ការជួសជុលសំណង)* សាលក្រមថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩៨ ស៊េរី គ លេខ៣៩ កថាខណ្ឌ៦២, ៦៣; រឿងក្តី *Blake តទល់នឹង ប្រទេសក្វាតេម៉ាឡា* សាលក្រមថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ កថាខណ្ឌ៣៧; រឿងក្តី *Bámaca Velásquez តទល់នឹង ប្រទេសក្វាតេម៉ាឡា (ការជួសជុលសំណង)* សាលក្រម ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០២ ស៊េរី គ លេខ៩១ កថាខណ្ឌ៣៣-៣៦។

[៤៨] រឿងក្តី *Aloeboetoe តទល់នឹង ប្រទេសសូរីណាម (ការជួសជុលសំណង)* សាលក្រម ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស៊េរី គ លេខ១៥ កថាខណ្ឌ៧១; រឿងក្តី *Panel Blanca តទល់នឹង ប្រទេសក្វាតេម៉ាឡា (ការជួសជុលសំណង)* សាលក្រម ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១ ស៊េរី គ លេខ៧៦ កថាខណ្ឌ៨៥, ៨៦; រឿងក្តី *កុមារតាមចិញ្ចើមថ្នល់ តទល់នឹង ប្រទេសក្វាតេម៉ាឡា (ការជួសជុលសំណង)* សាលក្រម ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០១ ស៊េរី គ លេខ៧៧ កថាខណ្ឌ៦៨; រឿងក្តី *Juan Humberto Sánchez តទល់នឹង ប្រទេសហុងឌូរ៉ាស* ស៊េរី គ លេខ៩ សាលក្រម ថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០០៣ កថាខណ្ឌ១៥២។

[៤៩] រឿងក្តី *Loayza Tamayo តទល់នឹង ប្រទេសប៉េរូ (ការជួសជុលសំណង)* សាលក្រម ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស៊េរី គ លេខ៤២ កថាខណ្ឌ៩២។

[៥០] រឿងក្តី *Blake តទល់នឹង ប្រទេសក្វាតេម៉ាឡា (ការជួសជុលសំណង)* សាលក្រម ថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ កថាខណ្ឌ៣៧[ឪពុកម្តាយ និងបងប្អូនប្រុសស្រីរបស់អ្នកបាត់ខ្លួន ដោយគ្មានភ័ស្តុតាងផ្សេងពីនេះ]; រឿងក្តី *Loayza Tamayo តទល់នឹង ប្រទេសប៉េរូ (ការជួសជុលសំណង)* សាលក្រម ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស៊េរី គ លេខ៤២ កថាខណ្ឌ៩២ [មនុស្សទាំងអស់ដែលមានចំណងគ្រួសារជិតស្និទ្ធ ពោលគឺជាកូន ឪពុកម្តាយ និងបងប្អូនប្រុសស្រី]; រឿងក្តី *Juan Humberto Sánchez តទល់នឹង ប្រទេសហុងឌូរ៉ាស* សាលក្រមថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០០៣ ស៊េរី គ លេខ៩៩ កថាខណ្ឌ១៥២; រឿងក្តី *អ្នកជំនួញ ១៩ នាក់ តទល់នឹង ប្រទេសកូឡុំប៊ី* សាលក្រម ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០០៤ ស៊េរី គ លេខ១០៩ កថាខណ្ឌ២៤៩ [កូន គូស្រករ ឪពុកម្តាយ និងបងប្អូនបង្កើត]។

៥១. ប្រការដែលគួរឱ្យកត់សម្គាល់នោះគឺថា គោលការណ៍ជាមូលដ្ឋាន បានកំណត់និយមន័យនៃពាក្យថា "ជនរងគ្រោះ" ក្នុងគោលការណ៍៨(៨) ថា៖

> "... ជនរងគ្រោះជាបុគ្គលដែលទទួលរងព្យសនកម្មជាលក្ខណៈបុគ្គលផង និងរួមគ្នាផង រួមទាំងព្យសនកម្មខាងផ្លូវកាយ ឬផ្លូវចិត្ត ការឈឺចាប់ផ្លូវចិត្ត ការបាត់បង់ផ្នែកសេដ្ឋកិច្ច ឬការខូចខាតនូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួន ...។ ក្នុងករណីសមស្រប និងដោយអនុលោមតាមច្បាប់ក្នុងប្រទេសផង ពាក្យថា "ជនរងគ្រោះ" ក៏បានរាប់បញ្ចូលផងដែរនូវគ្រួសារផ្ទាល់ ឬអ្នកនៅក្នុងបន្ទុករបស់ជនរងគ្រោះផ្ទាល់ និងបុគ្គលដែលបានទទួលរងព្យសនកម្មក្នុងការធ្វើអន្តរាគមន៍ជួយជនរងគ្រោះក្នុងពេលមានគ្រោះភ័យ ឬដើម្បីរារាំងមិនឱ្យក្លាយជាជនរងគ្រោះ"[៥១]។

៥២. ស.ច.ស មានការភ័ន្តច្រឡំទាំងលើអង្គច្បាប់ និងអង្គហេតុ នៅពេលធ្វើការសន្និដ្ឋានថា ម្ចាស់បណ្តឹងឧទ្ធរណ៍មិនមែនជា "ជនរងគ្រោះ" ដោយសារ "គោលការណ៍មូលដ្ឋាន និងការណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះ ។ល។ ... ពិតជាបានរួមបញ្ចូលសមាជិកគ្រួសារផ្ទាល់ ឬអ្នកក្នុងបន្ទុកមែន តែលុះត្រាតែអ្នកទាំងនោះបានទទួលរងព្យសនកម្ម "ក្នុងការជួយជនរងគ្រោះ" ...[៥២]"។

៥៣. ស.ច.ស មានការភ័ន្តច្រឡំផងដែរដែលសន្និដ្ឋានថា "ការមិនបានធ្វើអន្តរាគមន៍" របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដើម្បី "ជួយ" បងប្រុសគាត់ មានការពាក់ព័ន្ធនៅក្នុងការទាមទាររបស់គាត់ធ្វើជាជនរងគ្រោះនៃបទឧក្រិដ្ឋនោះ។ ត្រង់ចំណុចនេះ ស.ច.ស មានការភ័ន្តច្រឡំធ្ងន់ធ្ងរក្នុងការបកស្រាយវិធានជាមូលដ្ឋាន ដោយសារនិយមន័យមិនតម្រូវថា ជនរងគ្រោះត្រូវតែជា "សមាជិកគ្រួសារផ្ទាល់ ឬអ្នកនៅក្នុងបន្ទុក" *ផង និង* ជា "បុគ្គលដែលបានទទួលរងព្យសនកម្មក្នុងការធ្វើអន្តរាគមន៍ជួយជនរងគ្រោះ" *ផង* ទេ។ និយមន័យនេះបានប្រើពាក្យថា "ឬ" យ៉ាង

---

[៥១] គោលការណ៍៨(៨) គោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ (សូមមើលជើងទំព័រ១០)។

[៥២] និយមន័យនៃពាក្យថា "ជនរងគ្រោះ" នៅក្នុងគោលការណ៍មូលដ្ឋាន និងការណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះមានលក្ខណៈស្រដៀងគ្នានឹងនិយមន័យនៅក្នុង *គោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារឧក្រិដ្ឋកម្ម និងការបំពានអំណាច*។

ច្បាស់ណាស់ ដែលមានន័យថាជនរងគ្រោះអាចជាសមាជិកគ្រួសារ ឬ ជាអ្នកដែលបានទទួលរងព្យសនកម្មនៅពេលធ្វើអន្តរាគមន៍ជួយ ប៉ុន្តែមិនចាំបាច់មានលក្ខខណ្ឌតម្រូវទាំងពីរនោះឡើយ។

៥៤. សរុបមក មិនមានមូលដ្ឋានច្បាប់ពីច្បាប់ អ.វ.ត.ក ឬ ការអនុវត្ត ឬយុត្តាធិការតុលាការអន្តរជាតិនានាមកគាំទ្រដល់ការបដិសេធចោលពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ទេ ដោយសារគាត់បានបង្ហាញបានច្បាស់ថា គាត់បានទទួលរងព្យសនកម្ម ជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋដែលស្ថិតក្នុងការស៊ើបសួរ។ ដីកាសម្រេចរបស់ ស.ច.ស ដែលរងការជំទាស់ ទំនងជាសម្រេចដោយផ្អែកលើកត្តាផ្សេងក្រៅពីការបកស្រាយច្បាប់ និងការអនុវត្តច្បាប់ឱ្យបានសមរម្យ និងបានរំលោភយ៉ាងច្បាស់ទៅលើវិធាន២១(១)(គ), ២៣*ស្ទួន*(១)(ខ) មាត្រា៣.២(គ) នៃសេចក្តីណែនាំ និងគោលការណ៍ទី៤នៃគោលការណ៍មូលដ្ឋាន។ ដោយសារមានសំអាងហេតុនេះ ដីកាសម្រេចនេះគួរតែត្រូវបានច្រានចោល ហើយម្ចាស់បណ្តឹងឧទ្ធរណ៍គួរតែបានទទួលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើការអនុវត្តច្បាប់ដែលពាក់ព័ន្ធបានត្រឹមត្រូវ។

## ៣. មូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍

***ស.ច.ស បានរំលោភបំពានទៅលើវិធានផ្ទៃក្នុង វិធាន៥៦ និងវិធាន២១ គោលការណ៍មូលដ្ឋាននៃសិទ្ធិរបស់ជនរងគ្រោះ និងគោលការណ៍ជាសារវន្តនៃភាពយុត្តិធម៌ក្នុងដំណើរការនីតិវិធី ក្នុងការផ្តល់ព័ត៌មានជាសាធារណៈអំពីសំណុំរឿង០០៣***

### កង្វះខាតព័ត៌មានជាសាធារណៈអំពីដំណើរការនៃសំណុំរឿង០០៣

៥៥. តាមវិធាន៥៦(ក) នៃវិធានផ្ទៃក្នុង ស.ច.ស អាច "តាមរយៈផ្នែកកិច្ចការសាធារណៈ ផ្តល់ដោយរួមគ្នានូវព័ត៌មានពាក់ព័ន្ធទៅនឹងសំណុំរឿងដែលកំពុងស្ថិតនៅក្នុងការស៊ើបសួរ ប្រសិនបើយល់ឃើញថាជាការចាំបាច់ ដើម្បីធ្វើឱ្យសាធារណជនបានដឹងអំពីកិច្ចដំណើរការនីតិវិធី ឬដើម្បីកែតម្រូវព័ត៌មានមិនពិត ឬព័ត៌មានដែលនាំឱ្យមានការភ័ន្តច្រឡំ" ហើយតាមវិធាន៥៦(ខ)

នៃវិធានផ្ទៃក្នុង "ផ្តល់ការអនុញ្ញាតដោយរួមគ្នាដល់សារព័ត៌មាន ឬអ្នកដទៃទៀតដែលមិនមែនជាភាគីឱ្យចូលរួមដោយមានកម្រិតនៅក្នុងកិច្ចស៊ើបសួរ"។

៥៦. អង្គជំនុំជម្រះបានមើលឃើញថា សាធារណជនមានចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងសំណុំរឿងដែលខ្លួនកំពុងស៊ើបអង្កេត និងចោទប្រកាន់ ដោយរួមបញ្ចូលទាំងសំណុំរឿង០០៣។ បើទោះបីជាការស៊ើបអង្កេតមានលក្ខណៈសម្ងាត់បំផុតក៏ដោយ ក៏អង្គជំនុំជម្រះគួរព្យាយាមខ្លះៗក្នុងការផ្តល់ជូនយ៉ាងហោចណាស់នូវព័ត៌មាន ក៏ដូចជាការផ្តល់យោបល់ ដើម្បីឱ្យជនរងគ្រោះបានដឹងថាតើអ្វីនឹងកើតមាននៅក្នុងសំណុំរឿងទាំងនោះ ដូចដែលបានធ្វើឡើងនៅក្នុងសំណុំរឿង០០២ ដែលក្នុងសំណុំរឿង០០២ នេះ ស.ច.ស បានប្រកាសជាសាធារណៈអំពីវិសាលភាពនៃកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ មុនពេលសន្និដ្ឋានបញ្ចប់កិច្ចស៊ើបអង្កេតទាំងអស់នោះ[៥៣]។ លើសពីនេះទៅទៀត នៅក្នុងសំណុំរឿង ០០២ សេចក្តីសង្ខេបលម្អិតនៃកិច្ចស៊ើបអង្កេត ក៏ត្រូវបានប្រកាសជាសាធារណៈ ហើយជនរងគ្រោះក៏ទទួលបាននូវការជូនដំណឹងយ៉ាងសមស្រប[៥៤]។ សេចក្តីប្រកាសព័ត៌មានរបស់ ស.ច.ស ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ បានផ្តល់នូវគោលការណ៍ណែនាំជាសាធារណៈដំបូងបំផុត សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បើទោះបីជាការប្រកាសនេះមានលក្ខណៈយឺតយ៉ាវក៏ដោយចុះ។ ជនរងគ្រោះបាន

---

[៥៣] ក.ស.ច.ស "សេចក្តីថ្លែងការណ៍" ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ នៅ http://www.eccc.gov.kh/english/cabinet/press/138/ECCC_Press_Release_5_Nov_2009_Eng.pdf. ក្នុងសំណុំរឿង០០២ កសចស បានចេញនូវសេចក្តីថ្លែងការណ៍ដ៏មានប្រយោជន៍ តែយឺតយ៉ាវមួយ នៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ជូនដំណឹងដល់សាធារណៈជនអំពីអំពើប្រព្រឹត្តប្រឆាំងនឹងប្រជាជន និង/ក្រុមមនុស្សមួយចំនួន និងទីតាំងឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្រោម "វិសាលភាពនៃការស៊ើបអង្កេត" ហើយថែងថា "ប្រសិនបើជនរងគ្រោះចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ការទទួលរងនូវព្យសនកម្មរបស់ពួកគេត្រូវតែផ្ទាល់ខ្លួន និងដោយផ្ទាល់ ដែលជាប់ទាក់ទងនឹងស្ថានភាពអង្គហេតុមួយ ឬច្រើន ដែលបង្កើតបានជាមូលដ្ឋាននៃការស៊ើបសួរ ដែលកំពុងដំណើរការ"។

[៥៤] សូមមើលព័ត៌មានសាធារណៈរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុង http://www.eccc.gov.kh/en/articles/conclusion-judicial-investigation-case-002 ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០។

00746415



ទទួលដំណឹង បន្ថែមទៀតអំពីការពន្យារកាលបរិច្ឆេទក្នុងការដាក់ព័ត៌មានបន្ថែមសម្រាប់គាំទ្រដល់ការអះអាងរបស់ពួកគាត់ ក្រោយពីមានសេចក្តីប្រកាសព័ត៌មានមក[៥៥]។

៥៧. នៅក្នុងខែ មករា ឆ្នាំ ២០១០ នៅពេលដែលចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានសន្និដ្ឋានបញ្ចប់កិច្ចស៊ើបសួរនៅក្នុងសំណុំរឿង០០២ មានជនរងគ្រោះនៃរបបខ្មែរក្រហមប្រមាណ ៤.០០០ នាក់ បានដាក់ពាក្យសុំចូលរួមក្នុងដំណើរការជំនុំជម្រះ ព្រមទាំងទាមទារសំណង។ នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ចំនួនអ្នកដាក់ពាក្យសុំ ក្នុងចំនួន ៩៨% បានទទួលការអនុញ្ញាតឱ្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងចំនួន ២.០០០នាក់ដាក់បណ្តឹងឧទ្ធរណ៍ដោយជោគជ័យ[៥៦]។

៥៨. នៅក្នុងសំណុំរឿង០០៣ និង០០៤ ដែលតាមការប៉ាន់ប្រមាណមានជនរងគ្រោះប្រមាណជាងមួយសែននាក់នោះ[៥៧] ត្រូវបានរាំងជាប្រព័ន្ធមិនឱ្យចូលរួម ព្រោះមិនអាចស្វែងរកបាននូវព័ត៌មានអំពីឈ្មោះជនសង្ស័យ។ នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ គឺបន្ទាប់ពីបានបញ្ចប់នូវកិច្ចស៊ើបអង្កេតរយៈពេល២០ខែ នៃសំណុំរឿង០០៣ គឺនៅពេលដែលប្រកាសសន្និដ្ឋានបញ្ចប់ការស៊ើបអង្កេត អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺមានចំនួនបួនរូប។ បន្ទាប់ពីពន្យារកាលបរិច្ឆេទផុតកំណត់ ត្រឹមថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១១ គឺមានអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រឹមតែ ៣១៨ រូបប៉ុណ្ណោះ។

---

[៥៥] ការពន្យាពេលកំណត់បឋមនៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ បីសប្តាហ៍ ដែលត្រូវបានប្រកាសនៅថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១១។ ការពន្យាពេលមានប្រសិទ្ធភាពមួយថ្ងៃ (ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១១)។ សូមមើល សេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេត "សេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងសំណើសុំនានារបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងសំណុំរឿង០០៣" ចុះថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១១ នៅ http://www.eccc.gov.kh/sites/default/files/media/ECCC%20OCIJ%207%20June%202011%28Eng%29.pdf

[៥៦] អង្គបុរេជំនុំជម្រះ "សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកានានា របស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ D404/2/4។

[៥៧] "ការបិទសំណុំរឿងអាចឆ្លុះបញ្ចាំងអំពីទស្សនៈជាផ្លូវការរបស់ខ្មែរក្រហម" *The Cambodia Daily* ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រមុខ ដោយ Douglas Gillison។

៥៩. ចម្លើយសម្រាប់ "សំណួរចម្លើយអំពីសំណុំរឿង០០៣ (FAQs)" ត្រូវបានចុះផ្សាយនៅលើគេហទំព័រ អ.វ.ត.ក កាលពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១១[៥៨]។ ចម្លើយនេះធ្វើឡើងក្រោយពី ក.ស.ព បានចេញសេចក្តីប្រកាសព័ត៌មានថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ ដែលព្រះរាជអាជ្ញាអន្តរជាតិ បានជូនដំណឹងដល់សាធារណជន អំពីវិសាលភាពនៃកិច្ចស៊ើបសួរ ក្នុងសំណុំរឿង ០០៣ ព្រមទាំងកាលបរិច្ឆេទសម្រាប់អ្នកដែលចង់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការដាក់ពាក្យសុំ។ ដោយពិចារណាទៅលើការចុះផ្សាយ "FAQs" នៅលើអ៊ីនធឺណែត ក្រោយពីមានសេចក្តីប្រកាសព័ត៌មានរបស់ ក.ស.ព ព្រមទាំងពិចារណាទៅលើការបដិសេធរបស់ ស.ច.ស ចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីរនាក់ដំបូងនោះ គេអាចនឹងធ្វើការសន្និដ្ឋានមួយដ៏សមហេតុសមផលថា ការចេញផ្សាយនូវព័ត៌មាននេះ អាចបកស្រាយថាជាការព្រមានជាផ្លូវការ មិនឱ្យជនរងគ្រោះដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

៦០. នៅក្នុងសំណុំរឿង០០២ ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានអង្គភាពជនរងគ្រោះ (ដែលក្នុងពេលឥឡូវគឺអង្គភាពគាំពារជនរងគ្រោះ) សាកសួរថា តើគាត់ចង់ផ្ទេរពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១ ទៅក្នុងសំណុំរឿង០០២ ដែលឬទេ (ដែលការផ្ទេរនេះមានប្រសិទ្ធភាពក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២)។ ផ្ទុយពីសំណុំរឿង០០២ កម្រិតនៃការគោរពចំពោះជនរងគ្រោះដោយសារឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង០០៣ គឺគ្មានតែម្តង ដោយស្តែងចេញតាមរយៈកង្វះខាតនូវការផ្សព្វផ្សាយដល់ជនរងគ្រោះអំពីព័ត៌មានដែលពាក់ព័ន្ធនឹងសំណុំរឿងនេះ។ ក្រៅពីសេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិចេញ ដំណើរការស៊ើបអង្កេតក្នុង សំណុំរឿង០០៣ ក្នុងពេលកន្លងមក បានបង្ហាញថា ការគោរពចំពោះសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ មិនមែនជា ការងារអាទិភាពរបស់តុលាការនោះទេ ព្រោះជនរងគ្រោះត្រូវបានបដិសេធដោយប្រសិទ្ធភាពនូវឱកាសក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រោះថាកាលបរិច្ឆេទសម្រាប់ការដាក់

---

[៥៨] "សំណួរដែលគេសាកសួរញឹកញាប់ជាងគេអំពីសំណុំរឿង០០៣" នៅ http://www.eccc.gov.kh/en/articles/frequently-asked-questions-about-case-003.

00746417



ពាក្យសុំត្រូវបញ្ចប់នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ (ដោយអនុលោមទៅតាមវិធាន២៣ ស្ទួន(២) នៃវិធានផ្ទៃក្នុង) ហើយការពន្យារកាលបរិច្ឆេទផុតកំណត់ ត្រូវបាន ប្រកាសនៅថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១ គឺរយៈពេលតែមួយថ្ងៃប៉ុណ្ណោះ មុនពេល ការពន្យារជាក់ស្តែង ផុតកំណត់នោះ។

៦១. ស.ច.ស មិនត្រឹមតែមិនបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួនក្នុងការជូនដំណឹងដល់សាធារណជន តាមវិធាន៥៦ នៃវិធានផ្ទៃក្នុងប៉ុណ្ណោះទេ តែ ស.ច.ស ថែមទាំងបានធ្វើទុក្ខបុកម្នេញព្រះរាជអាជ្ញាអន្តរជាតិនៅពេលដែលព្រះរាជអាជ្ញាអន្តរជាតិបំពេញនូវតួនាទីរបស់ខ្លួនក្នុងការ "ផ្តល់ដល់សាធារណជននូវសេចក្តីសង្ខេបនៃព័ត៌មានដែលបាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយគិតទៅដល់សិទ្ធិរបស់ជនជាប់ចោទ និងផលប្រយោជន៍របស់ជនរងគ្រោះរបស់សាក្សី និងរបស់បុគ្គលដទៃទៀតដែលមានរៀបរាប់នៅក្នុងនោះ ព្រមទាំងលក្ខខណ្ឌតម្រូវនៃការស៊ើបអង្កេត" ដោយអនុលោមទៅតាមវិធាន ៥៤ នៃវិធានផ្ទៃក្នុង តាមរយៈការចោទប្រកាន់ពីបទ "ប្រមាថមាក់ងាយតុលាការ"[៩៩]។

៦២. សេចក្តីប្រកាសព័ត៌មានរបស់ព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ ដោយផ្អែកតាមឆន្ទានុសិទ្ធិ ដូចមានចែងក្នុងវិធាន ៥៤ នៃវិធានផ្ទៃក្នុង មិនអាចធ្វើឱ្យ ស.ច.ស បានរួចផុតពីការទទួលខុសត្រូវ ក្នុងការផ្តល់ដល់សាធារណជន ជនរងគ្រោះ និងអ្នកដែលអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឱ្យបានគ្រប់គ្រាន់នូវព័ត៌មានអំពីអត្តសញ្ញាណរបស់ជនត្រូវចោទ ព្រមទាំងវិសាលភាពនៃកិច្ចស៊ើបសួរ ក្នុងសំណុំរឿង០០៣ នោះឡើយ។

៦៣. ការប្រព្រឹត្តរបស់ ស.ច.ស នៅក្នុងសំណុំរឿង០០៣ គឺជាការរំលោភបំពានទៅលើគោលការណ៍ជាមូលដ្ឋាន ដែលចែងថា "ជនរងគ្រោះ ត្រូវទទួលបាននូវសេចក្តីមេត្តា និងការគោរពចំពោះសេចក្តីថ្លៃថ្នូររបស់ពួកគាត់។ ជនរងគ្រោះមានសិទ្ធិទទួលបាននូវយន្តការនៃយុត្តិធម៌ និងការទទួលបាននូវសំណង ដូចមានចែងក្នុងច្បាប់ជាតិ សម្រាប់រាល់ព្យសនកម្មទាំងឡាយណា

[៩៩] James O'Toole, "Cayley in the crosshairs", កាសែតភ្នំពេញប៉ុស្តិ៍, ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ១។

ដែលពួកគាត់បានទទួល"[៦០] ហើយ "ជនរងគ្រោះត្រូវទទួលបានការជូនដំណឹងអំពីសិទ្ធិរបស់ពួកគាត់ ក្នុងការស្វែងរកនូវសំណងតាមរយៈយន្តការដូចបានរៀបរាប់"[៦១]។

៦៤. ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើជនរងគ្រោះដែលបានបង្ហាញពីភាពក្លាហានឈានមុខពេញទំហឹង ដើម្បីប្រឈមជាមួយនឹងភាពតក់ស្លុត ដែលមិនអាចនិយាយចេញមកបាន កាលពីអតីតនោះ ប្រភេទ "សំអាងហេតុ" ដែល ស.ច.ស បានផ្តល់ចំពោះការអះអាងថា ជនរងគ្រោះមិនបានធ្វើអ្វីទាល់តែសោះ ដើម្បីបញ្ជាក់ថា ក្តីរំពឹងនានាដែលមានចំពោះកិច្ចដំណើរការនីតិវិធីតុលាការរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺមិនមែនជាក្តីរំពឹងដែលមិនត្រឹមត្រូវនោះទេ។ ជាពិសេស ស.ច.ស បានរំលោភបំពានគោលការណ៍៦ នៃគោលការណ៍ជាមូលដ្ឋាន ដែលបានចែងថា៖

> ការឆ្លើយតបរបស់ដំណើរការផ្នែករដ្ឋបាល ឬផ្នែកតុលាការ ចំពោះតម្រូវការរបស់ជនរងគ្រោះ គួរទទួលបានការសម្របសម្រួលដោយការ៖
>
> ក. **ជូនដំណឹងដល់ជនរងគ្រោះ អំពីតួនាទី និងវិសាលភាព អំពីពេលវេលា និងការវិវឌ្ឍនៃដំណើរការនីតិវិធី** ព្រមទាំងពីការសម្រេចសេចក្តីនៅក្នុងសំណុំរឿងរបស់ពួកគាត់ ពិសេសនៅពេលដែលរឿងក្តីនេះទាក់ទិននិងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ និងក្នុងករណីដែលជនរងគ្រោះស្នើសុំឱ្យមានការផ្តល់នូវព័ត៌មានទាំងនេះ។
>
> ខ. អនុញ្ញាតឱ្យជនរងគ្រោះបញ្ចេញនូវទស្សនៈ និងការព្រួយបារម្ភរបស់ពួកគាត់ ហើយទស្សនៈ និងការបារម្ភរបស់ជនរងគ្រោះត្រូវទទួលបាននូវការពិចារណានៅតាមដំណាក់កាលដ៏សមស្របក្នុងដំណើរការនីតិវិធី ក្នុងករណីដែលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ជនរងគ្រោះបានទទួលរងនូវផលប៉ះពាល់ តែមិនត្រូវឱ្យមានបុរេនិច្ឆ័យចំពោះជនជាប់ចោទ ហើយត្រូវស្របទៅតាមប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាតិដែលពាក់ព័ន្ធ។
>
> គ. **ផ្តល់នូវជំនួយសមស្របដល់ជនរងគ្រោះ នៅក្នុងដំណើរគតិយុត្តិទាំងអស់។**
>
> ឃ. **ចាត់វិធានការដើម្បីកាត់បន្ថយជាអតិបរមានូវការរំខានដល់ជនរងគ្រោះ** ហើយក្នុងករណីចាំបាច់ត្រូវការពារនូវការសម្ងាត់ និងធានានូវសុវត្ថិភាពរបស់ជនរងគ្រោះ និង

---

[៦០] គោលការណ៍៤ នៃគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ (សូមមើលជើងទំព័រ ១២)។

[៦១] គោលការណ៍៥ ដូចជើងទំព័រខាងលើ។

ក្រុមគ្រួសារ ព្រមទាំងសាក្សីនានា ក្នុងនាមជនរងគ្រោះ ដោយមិនឱ្យពួកគាត់ទទួលរង នូវការបំភិតបំភ័យ និងការសងសឹកនានា។

ង. **ជៀសវាងនូវការពន្យារពេលដែលមិនចាំបាច់** ក្នុងការសម្រេចសេចក្តីលើសំណុំរឿង ព្រមទាំងការអនុវត្តនូវដីកា ឬក្រឹត្យនានា ក្នុងការផ្តល់នូវសំណងទៅដល់ជនរងគ្រោះ (គូសបញ្ជាក់បន្ថែម)។

៦៥. ដោយមិនបានបំពេញតួនាទីរបស់ខ្លួនក្នុងការជូនដំណឹងដល់សាធារណជន ដោយអនុលោមតាមវិធាន៥៦ នៃវិធានផ្ទៃក្នុង ស.ច.ស មិនត្រឹមតែបានរំលោភបំពានទៅលើគោលការណ៍ទី៦ ប៉ុណ្ណោះទេ តែ ស.ច.សថែមទាំងបានបំពានទៅលើវិធាន២១ នៃវិធានផ្ទៃក្នុង ចំពោះការគ្រប់គ្រងរបស់ ស.ច.ស ទៅលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងបំពានលើដំណើរការស៊ើបអង្កេតរបស់ខ្លួនថែមទៀតផង។ ជាពិសេស ស.ច.ស បានបំពានលើវិធាន២១(គ) នៃវិធានផ្ទៃក្នុង ដែលតម្រូវឱ្យផ្តល់ព័ត៌មានដល់ជនរងគ្រោះ[៦២] ហើយបើនិយាយឱ្យទូលំទូលាយបន្ថែមទៀតនោះ ស.ច.ស បានបំពានលើគោលការណ៍ជាសារវន្តនៃភាពយុត្តិធម៌ក្រោមច្បាប់អន្តរជាតិ[៦៣]។

៦៦. ស.ច.ស បានបដិសេធបន្ថែមទៀតទៅលើសំណើររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី សុំចូលមើលសំណុំរឿង ដែលការបដិសេធនេះគឺមិនមានមូលដ្ឋានផ្លូវច្បាប់ឡើយ[៦៤]។ ការបដិសេធនេះគឺរាំងស្ទះដល់លទ្ធភាពរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលជាតំណាងតាមផ្លូវច្បាប់ចំពោះ

---

[៦២] វិធាន២១ នៃវិធានផ្ទៃក្នុងចែងថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព... ក្នុងបរិបទនេះ... (គ) អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី..."។

[៦៣] គោលការណ៍៤ និង៦ នៃគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ (សូមមើលជើងទំព័រ ១២)។

[៦៤] រហូតមកដល់ពេលនេះ មិនមានចម្លើយតបណាមួយពីក.ស.ច.ស ចំពោះសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំចូលមើលសំណុំរឿង០០៣។

00746420



បណ្តឹងរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការកំណត់នូវមូលដ្ឋានអង្គហេតុ និងអង្គច្បាប់ឱ្យបានសមស្រប ដើម្បីគាំទ្រដល់បណ្តឹងរបស់កូនក្តីខ្លួន។

## ៤. មូលដ្ឋានទីបួននៃបណ្តឹងឧទ្ធរណ៍

### *ស.ច.ស បានរំលោភបំពានវិធាន ២១(១) វិធាន ២១(១)(គ) វិធាន ២៣(១) នៃវិធានផ្ទៃក្នុង ស្តីពីគោលការណ៍ជាសារវន្តនៃការតបស្នងដោយប្រសិទ្ធភាព សម្រាប់ជនរងគ្រោះ និងសិទ្ធក្នុងការទទួលបានបាននូវសេចក្តីសម្រេចដែលមានសំអាងហេតុ តាមរយៈការបដិសេធពាក្យសុំជាជម្រើស ដោយយោងភាពចាំបាច់នៃការពន្លឿនសវនាការ និងការពេញចិត្តក្នុងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០១ និង០០២*

៦៧. ស.ច.ស បានបដិសេធពាក្យសុំនៅក្នុងជម្រើសទីពីរ និងទីបី ដោយសារ៖

> "ការទទួលយកពាក្យសុំ នឹងមិនស្របទៅនឹងគោលការណ៍នៃភាពឆាប់រហ័សនៃនីតិវិធី ដែលចែងក្នុងវិធាន២១(៤) ឡើយ ដោយហេតុថា អំពើឧក្រិដ្ឋដែលប្រព្រឹត្តនៅមន្ទីរសន្តិសុខ ស-២១ ដែលបានចោទប្រកាន់ ក៏ជាផ្នែកនៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ ហើយអ្នកដាក់ពាក្យសុំកំពុងអនុវត្តសិទ្ធជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ ហើយអ្នកដាក់ពាក្យសុំកំពុងអនុវត្តសិទ្ធជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនោះផងដែរ និងថែមទាំងបានអនុវត្តសិទ្ធជាដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១ ក្នុងអំឡុងពេលនៃដំណើរការជំនុំជម្រះសំណុំរឿង ០០១ ផងដែរ"[៦៥]។

៦៨. មូលហេតុនៃការបដិសេធមួយផ្សេងទៀតនេះបណ្តាលឱ្យមានមូលហេតុជាទូទៅមួយ សម្រាប់អនុវត្តទៅលើអ្នកពាក្យសុំ ដែលបានក្លាយទៅជាដើមបណ្តឹងរដ្ឋប្បវេណីរួចទៅហើយ នៅក្នុងសំណុំរឿងមួយ ក្នុងចំណោមបណ្តាសំណុំរឿងឯទៀតនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ តាមការយល់ដឹងរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺមានតែដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលសិទ្ធឱ្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅ ក្នុងសំណុំ

---

[៦៥] ក.ស.ច.ស "ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់[redacted]" ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ D11/4/3 កថាខណ្ឌ១០។

រឿង០០១ និង/ឬ ០០២ ដែលបានដាក់ពាក្យសុំតាំងខ្លួននៅក្នុងសំណុំរឿង០០៣[៦៦]។ ដូច្នេះ យោងមូលហេតុនេះ អាចសន្និដ្ឋានសម្រាប់ការបដិសេធភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានថា ស.ច.ស មានចេតនាបដិសេធ នូវរាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនាពេលបច្ចុប្បន្ន *ទាំងអស់* នៅក្នុងសំណុំ រឿង ០០៣។ ម្យ៉ាងវិញទៀត កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០៣ មិនបានរួមបញ្ចូលការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

៦៩. ការកំណត់បែបនេះ គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរមួយទៅលើខ្លឹមសារ និងឆន្ទៈរបស់វិធានផ្ទៃក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានអន្តរជាតិនានា។ ការមិនរួមបញ្ចូលអ្នកដាក់ពាក្យសុំ គឺបណ្តាលមកពី (i) មូលហេតុកិច្ចដំណើរការនីតិវិធីឆាប់រហ័ស (ដោយមិនបានវាស់ស្ទង់គោលបំណងនេះ ជាមួយនឹងសិទ្ធរបស់ជនរងគ្រោះ) និង (ii) ការចូលរួមរបស់អ្នកដាក់ពាក្យសុំនៅក្នុងសំណុំរឿងនានា ក្នុងពេលបច្ចុប្បន្ននេះ មិនមានមូលដ្ឋានច្បាប់ និងបណ្តាលឱ្យមានសេចក្តីផ្តើមដោយលាក់លៀមមួយ ស្តីអំពីលក្ខណៈសម្បត្តិបន្ថែមសម្រាប់ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[៦៧]។ ស.ច.ស បានរំលោភដោយចេតនាទៅលើច្បាប់ និងវិធានផ្ទៃក្នុងជាធរមាន តាមរយៈការបដិសេធអ្នកដាក់ពាក្យសុំនៅក្នុងជម្រើសដោយផ្អែកលើមូលដ្ឋាននេះ។ ការមិនទទួលស្គាល់ភាពត្រឹមត្រូវតាមច្បាប់របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបំពេញតាមលក្ខណៈសម្បត្តិភាពអាចទទួលយកបានតាមច្បាប់ របស់

---

[៦៦] នេះត្រូវបានធ្វើសេចក្តីសន្និដ្ឋានចេញពីការពិតដែលថា វាមិនទំនងទេដែលថាអង្គការមិនមែនរដ្ឋាភិបាលបានអនុវត្តសកម្មភាពផ្សព្វផ្សាយក្នុងសំណុំរឿង០០៣ ដើម្បីជូនដំណឹងដល់ប្រជាជន ហើយតុលាការក៏ដូចគ្នាដែរ។ ដូច្នេះ មានតែដើមបណ្តឹងរដ្ឋប្បវេណីស្រាប់ប៉ុណ្ណោះ ដែលបានដាក់ពាក្យសុំក្នុងសំណុំរឿង០០៣។ បន្ថែមលើនេះទៀត ដោយសារតែពុំមានព័ត៌មានអំពីសំណុំរឿងនេះ អង្គការមិនមែនរដ្ឋាភិបាលពុំអាចជូនដំណឹងអ្វីបានទៅដល់ជនរងគ្រោះឡើយ។ ផ្ទុយទៅវិញ តុលាការទាំងមូលរួមចំណែកបង្កឱ្យមានការលំបាកដល់ជនរងគ្រោះ ក្នុងការដាក់ពាក្យសុំ ដោយសារតែខ្លួនបានលុបចោលទម្រង់បែបបទព័ត៌មានជនរងគ្រោះចេញពីគេហទំព័ររបស់ខ្លួន នៅពេលដែលពេលកំណត់សម្រាប់ការដាក់ពាក្យនៅមានសុពលភាពនៅឡើយ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមធ្វើការប្តឹងតវ៉ាចំពោះបញ្ហានេះទៅផ្នែកកិច្ចការសាធារណៈ និងអង្គភាពគាំពារជនរងគ្រោះ។

[៦៧] ចៅក្រមត្រូវបកស្រាយច្បាប់ ប៉ុន្តែមិនត្រូវបានអនុញ្ញាតឱ្យបន្ថែមធាតុផ្សំសំខាន់ៗឡើយ។

ស.ច.ស បង្ហាញឱ្យឃើញជាថ្មីម្តងទៀតថា ស.ច.ស កំពុងតែឆ្ពោះទៅរកការបដិសេធចោលសំណុំរឿង ០០៣។

៧០. វិធីសាស្ត្រដែលនៅមិនទាន់បានបញ្ជាក់មួយនេះ នៅបានបង្កឱ្យមានការរំលោភទៅលើគោលការណ៍សច្ចភាពផ្លូវច្បាប់ ដោយ ដើមបណ្តឹងរដ្ឋប្បវេណីគ្រប់ៗរូប ដែលបានទទួលការអនុញ្ញាតឱ្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០១ រួចហើយ ត្រូវបានអង្គភាពគាំពារជនរងគ្រោះ ស្នើ ព្រមទាំង *អញ្ជើញ* ឱ្យចូលរួមនៅក្នុងសំណុំរឿង ០០២ បន្ទាប់ពីបានចូលរួមនៅក្នុងសំណុំរឿង ០០១ ហើយ។

៧១. ជាមួយនឹងមូលហេតុនៃការបដិសេធជាជម្រើសផ្សេងនេះ (ចំពោះទស្សនៈរបស់ ស.ច.ស ដែលអាចជាជំហរដោយខ្លួនឯង ប្រសិនបើមូលហេតុដទៃទៀត មិនត្រូវបាន អង្គបុរេជំនុំជម្រះទទួលយក) ស.ច.ស មិនបានអនុវត្តវិធានផ្ទៃក្នុងឱ្យបានត្រឹមត្រូវ ដែលបកស្រាយយ៉ាងច្បាស់ពីលក្ខណៈសម្បត្តិដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ការចូលរួមនៅក្នុងសំណុំរឿង ០០២ ដោយនឹងត្រូវត្រួតពិនិត្យទៅលើទីតាំងឧក្រិដ្ឋកម្មដូចគ្នានោះ ឬបានចូលរួមនៅក្នុងសំណុំរឿង ០០១ រួចទៅហើយ មិនមែនប៉ះពាល់ដល់សុពលភាពសម្រាប់ការចូលរួមរបស់បុគ្គល នៅក្នុងសំណុំរឿង ០០៣ នោះទេ។ សំណុំរឿងផ្សេងគ្នាបង្ហាញឱ្យឃើញថា មានចុងចោទផ្សេងៗគ្នា ដោយចុងចោទទាំងនោះ មានតួនាទី និងការទទួលខុសត្រូវក៏ខុសប្លែកពីគ្នាផងដែរ ចំពោះកន្លែងឧក្រិដ្ឋកម្មដូចគ្នានោះ។ ចំណុចដែល ស.ច.ស បានលើកឡើងមិនមែនជាទឡ្ហីករណ៍ ដែលមានសុពលភាព ឬលក្ខណៈសម្បត្តិផ្លូវច្បាប់ដែលមាន សម្រាប់សេចក្តីសម្រេចនានាពាក់ព័ន្ធនឹងភាពអាចទទួលយកបានរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នោះទេ។

៧២. សំអាងហេតុនៅក្នុងជម្រើសនេះ គឺជា "ការបន្ថែមមួយទៅលើ" ការសម្រេចដែលមានលក្ខណៈ ហួសហេតុរួចទៅហើយមួយ និងបណ្តាលឱ្យមានការរំលោភបំពានធ្ងន់ធ្ងរមួយទៅលើសិទ្ធមូលដ្ឋានជាសារវន្តរបស់ជនរងគ្រោះ (i) ក្នុងការដឹងឮ (ii) ក្នុងការស្វែងរកការពិត និង (iii) ក្នុងការទទួលបានដំណោះស្រាយមួយប្រកបដោយប្រសិទ្ធិភាព រួមទាំងសំណងផងដែរ។ ស.ច.ស បានដកហូតពីអ្នកពាក្យសុំទាំងស្រុង នូវសិទ្ធក្នុងការអនុវត្តសិទ្ធមូលដ្ឋាន

ជាសារវន្ត ទាំងនេះនៅក្នុងសំណុំរឿង ០០៣ ដែលមិនអាចធ្វើការតបស្នងបាន តាមរយៈការចូលរួម នៅក្នុងសវនាការមួយផ្សេងទៀត ដែលមានជនជាប់ចោទខុសគ្នានោះទេ។

៧៣. លើសពីនេះទៀត "សំអាងហេតុ" នេះ គឺជាសំអាងហេតុដែលមិនសមហេតុសមផលទាល់តែសោះ ដោយលើកឡើងថា រាល់ការបដិសេធដោយផ្អែកលើមូលហេតុនេះ និងបណ្ដាលឱ្យមានការសម្រេចមិនត្រឹមត្រូវមួយ ដោយសំអាងថា ខកខានក្នុងការផ្ដល់សំអាងហេតុនានា (ត្រឹមត្រូវ និងគ្រប់គ្រាន់) ដោយសេចក្ដីសម្រេចផ្ទាល់ គឺជាការរំលោភបំពានទៅលើវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលឯកសារច្បាប់ទាំងពីរនេះ សុទ្ធតែតម្រូវឱ្យមានសេចក្ដីសម្រេចដោយមានសំអាងហេតុ។ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី យោងទៅលើករណីផ្លូវច្បាប់ ស្ដីអំពីលក្ខខណ្ឌតម្រូវឱ្យមានការសម្រេចដោយមានសំអាងហេតុ ផ្អែកលើកថាខណ្ឌ ៥០ -កថាខណ្ឌ ៦៣ នៃបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅក្នុងខេត្តកែប[៦៨]។

៧៤. គោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌តម្រូវថា ជនរងគ្រោះគួរត្រូវបានទទួលព័ត៌មានអំពីហេតុផល ដែលបទឧក្រិដ្ឋដែលពួកគាត់បានជួបប្រទះ និងព្យសនកម្មដែលពួកគាត់បានទទួលរងនោះត្រូវបានបដិសេធដោយតុលាការថា មិនអាចទទួលយកដើម្បីជួយដល់បណ្ដឹងទាមទាររបស់ពួកគាត់នោះទេ។ មូលហេតុជាប់ពាក់ព័ន្ធមួយផ្សេងទៀត សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសូមស្នើឱ្យអង្គចៅក្រមនៃអង្គបុរេជំនុំជម្រះ បដិសេធផងដែរនូវដីការបស់ ស.ច.ស ពាក់ព័ន្ធនឹង [redacted] ដោយផ្អែកថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធ ត្រូវតែដាក់ចេញដោយមានសេចក្ដីសម្រេចប្រកបដោយសំអាងហេតុដែលអាចយល់បាន ព្រមទាំងត្រឹមត្រូវជាក់ស្ដែងតាមផ្លូវច្បាប់ និងអង្គច្បាប់។

## ៥. មូលដ្ឋានទីប្រាំនៃបណ្ដឹងឧទ្ធរណ៍

---

[៦៨] យោងទៅលើសំណុំរឿង០០២ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានអាសយដ្ឋាននៅក្នុងខេត្តកែប ចុះថ្ងៃទី៦ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D392/3/1 កថាខណ្ឌ៥០-៦៣។

ស.ច.ស បានរំលោភបំពានវិធាន១៤(១) វិធាន៥៥(៥) មាត្រា១០ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មាត្រា៥(២) និង(៣) នៃកិច្ចព្រមព្រៀង ដោយសារតែ ស.ច.ស មិនបានស៊ើបអង្កេតដោយត្រឹមត្រូវ និងឯករាជ្យ ក្នុងសំណុំរឿង០០៣

៧៥. បណ្តឹងឧទ្ធរណ៍ក្លាយទៅជាការដាក់ជូននូវសំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដោយ ស.ច.ស មិនបានស៊ើបអង្កេតដោយត្រឹមត្រូវ និងឯករាជ្យក្នុងសំណុំរឿង០០៣ ដោយ ស.ច.ស

(ក) មិនបានស៊ើបអង្កេតលើអង្គហេតុនានា ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់ការិយាល័យសហព្រះរាជអាជ្ញា

(ខ) បណ្តោយឱ្យមានការសម្រេចចិត្តបែបនយោបាយចូលមកឡូកឡំជាមួយនឹងការកំណត់តាមផ្លូវច្បាប់របស់ខ្លួន

(គ) មិនបានបំពេញតាមតួនាទី មុខងារ និងភារកិច្ចតាមផ្លូវច្បាប់ របស់ខ្លួន ដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង

(ឃ) បានកំណត់ភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើការយល់ឃើញទុកជាមុនថា ជនសង្ស័យទាំងឡាយនៅក្នុងសំណុំរឿង០០៣ មិនស្ថិតនៅក្នុងយុត្តាធិការផ្ទាល់របស់អង្គជំនុំជម្រះ

ចំណុចទាំងនេះ ទោះជាដោយឡែកពីគ្នា និងរួមបញ្ចូលគ្នាក៏ដោយ ក៏បង្ហាញថា ស.ច.ស មានកំហុសទាំងអង្គហេតុ និងអង្គច្បាប់ ចំពោះតួនាទី និងមុខងារសមស្របដែល ស.ច.ស ត្រូវបំពេញនៅក្នុងអង្គជំនុំជម្រះ ហើយការប្រព្រឹត្តដូច្នេះ គឺ ស.ច.ស បានរំលោភលើវិធានផ្ទៃក្នុង ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ព្រមទាំងកិច្ចព្រមព្រៀង អ.វ.ត.ក។

ក) មិនបានស៊ើបអង្កេតលើអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរបន្ថែម

៧៦. យោងទៅតាម មាត្រា៥(២) និង (៣) នៃកិច្ចព្រមព្រៀង, មាត្រា១០ថ្មី នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក និងវិធាន១៤(១), វិធាន៥៥(៥) នៃវិធានផ្ទៃក្នុង សហចៅក្រម(ស៊ើបអង្កេត)

"ត្រូវឯករាជ្យ ហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ" ហើយ "សហចៅក្រមស៊ើបអង្កេតត្រូវដំណើរការស៊ើបអង្កេតដោយមិនលម្អៀង និងឯករាជ្យ"។

៧៧. ការបដិសេធលើបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ គឺផ្អែកលើមូលដ្ឋានដែលថា ស.ច.ស មិនបានស៊ើបអង្កេតដោយត្រឹមត្រូវ និងឯករាជ្យ ទៅលើអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលសហព្រះរាជអាជ្ញាបានបញ្ជូនទៅកាន់ ស.ច.ស។ ជាពិសេសគឺ ស.ច.ស មិនបានពិចារណាទៅលើអង្គហេតុដែលអ្នកដាក់ពាក្យសុំបានលើកឡើង។ អង្គហេតុដែលស្ថិតក្រោមកិច្ចស៊ើបសួរ រួមមាន "ចាប់ចង [redacted] ព្រមទាំងការឃុំខ្លួនដោយខុសច្បាប់ ការបញ្ជូនទៅមន្ទីរ ស២១ ឬក៏ការសម្លាប់" ដូចដែលបានប្រកាសក្នុង [redacted] បានដាក់ជនជាប់សង្ស័យដែលរងការចោទប្រកាន់ [redacted] ឱ្យស្ថិតក្រោមយុត្តាធិការផ្ទាល់របស់ អង្គជំនុំជម្រះ។

៧៨. ចាប់តាំងពីថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២00៩ គឺនៅពេលដែល ស.ច.ស បានទទួលយកនូវដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[៦៩] (សំណុំរឿង00៣) រួចមក មានរយៈពេលជាងម្ភៃខែ ដែល ស.ច.ស មិនបានធ្វើកិច្ចស៊ើបអង្កេតឱ្យបានត្រឹមត្រូវ។ នៅថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២0១១ គឺក្រោយពីស.ច.ស បានទទួលយកកិច្ចស៊ើបអង្កេតនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី២ រយៈពេលជិត ១៧ ខែ ទើប ស.ច.ស បានជូនដំណឹងជាសាធារណៈថា មិនមានការស៊ើបអង្កេតតាមទីកន្លែងនោះឡើយ ហើយ "ការងារក្នុងពេលបច្ចុប្បន្នគឺផ្តោតទៅលើការពិនិត្យ និងវិភាគទៅលើឯកសារដែលមានស្រាប់នៅក្នុងសំណុំរឿង ជាពិសេសឯកសារដែលមាននៅ

[៦៩] សូមមើលព័ត៌មានសាធារណៈត្រង់ http://www.eccc.gov.kh/en/articles/acting-international-co-prosecutor-requests-investigation-additional-suspects ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២00៩។

ក្នុងសំណុំរឿង០០១ និង០០២ពីមុន"[៧០]។ ក្រោយពីការប្រកាសព័ត៌មាននេះបន្តិច មានការប្រកាសជាសាធារណៈអំពីការបញ្ចប់សំណុំរឿង។

៧៩. *របាយការណ៍ ស្តីពីការវិវឌ្ឍនាពេលថ្មីៗនេះ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា របស់អង្គការ* OSJI ចេញផ្សាយនៅក្នុងខែមិថុនា ឆ្នាំ២០១១ បានកត់សម្គាល់ថា នៅខណៈដែលលោកចៅក្រម Marcel Lemonde ស្ថិតនៅក្នុងតំណែងនៅឡើយ *របាយការណ៍តុលាការ* ដែលត្រូវបានបោះពុម្ពផ្សាយជារៀងរាល់ខែរបស់ផ្នែកកិច្ចការសាធារណៈ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានដកស្រង់ការស៊ើបអង្កេតនៅទីកន្លែងក្នុងសំណុំរឿង ០០៣ ប៉ុន្តែ ការស៊ើបអង្កេតដល់ទីកន្លែងទាំងនោះ ត្រូវបានរាយការណ៍ថា ធ្វើឡើងដោយបុគ្គលិកអន្តរជាតិប៉ុណ្ណោះ"[៧១]។ *របាយការណ៍តុលាការ* មួយចំនួនដែលត្រូវបោះពុម្ពនៅអំឡុង កាលបរិច្ឆេទដែលលោកចៅក្រម Blunk ចូលកាន់តំណែង (ខែធ្នូ ឆ្នាំ២០១០) និងថ្ងៃទី ២៩ ខែមេសា ដែលជាកាលបរិច្ឆេទនៃការបិទការស៊ើបអង្កេតសំណុំរឿង០០៣ នោះ បានដកស្រង់ថា "គ្មានការស៊ើបអង្កេតដល់ទីកន្លែងនោះទេ"។ ជាទូទៅ "ការវិវឌ្ឍ" ដែលត្រូវបានដកស្រង់នៅក្នុងការស៊ើបអង្កេត គឺការពិនិត្យមើលឯកសារនានា ដែលការិយាល័យសហចៅក្រមស៊ើបអង្កេតមានរួចទៅហើយ និងការរៀបចំ "អនុស្សារណៈផ្សេងៗ ស្តីអំពីបញ្ហាផ្នែកច្បាប់ដែលស្មុគស្មាញ"[៧២]។

[៧០] សូមមើលសេចក្តីថ្លែងការណ៍សាធារណៈ ត្រង់ http://www.eccc.gov.kh/en/articles/statement-co-investigating-judges-regarding-case-files-003-and-004 ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១១។

[៧១] "របាយការណ៍តុលាការ" ការបោះពុម្ពផ្សាយរបស់អវតក ប្រចាំខែ មករា ឆ្នាំ ២០១១ ទំព័រទី៧ ចែងថា "... បេសកកម្មចុះតាមមូលដ្ឋានពាក់ព័ន្ធនឹងសំណុំរឿង០០៣មួយ នៅភ្នំពេញ នៅថ្ងៃទី១ ខែ ធ្នូ"។ នេះជាបេសកកម្មចុះតាមមូលដ្ឋាន ដែលគេបានរាយការណ៍ចុងក្រោយគេបង្អស់ ហើយត្រូវបានធ្វើឡើងនៅថ្ងៃ ដែលចៅក្រម Blunk ចូលកាន់មុខនាទីជាផ្លូវការរបស់លោក។ *សូមមើលផងដែរ* ក្នុងការបោះពុម្ពផ្សាយរបស់អ.វ.ត.ក "របាយការណ៍តុលាការ" ប្រចាំខែ វិច្ឆិកា ឆ្នាំ ២០១០ នៅទំព័រទី៨។ *ក៏សូមមើលផងដែរ* Justice Initiative ប្រចាំខែ ធ្នូ ទំព័រទី១១ ។ ក៏សូមមើល របាយការណ៍ស្តីពីការជ្រៀតជ្រែកផ្នែកនយោបាយ របស់ Justice Initiative ទំព័រទី២១។

[៧២] សូមមើល ការបោះពុម្ពផ្សាយរបស់អ.វ.ត.ក "របាយការណ៍តុលាការ" ប្រចាំខែ កុម្ភៈ ឆ្នាំ ២០១១ នៅទំព័រទី៧ ៖ "ពុំមានការស៊ើបអង្កេតអ្វីឡើយ ក្នុងអំឡុងពេលរៀបចំរបាយការណ៍នេះ" និង ការបោះពុម្ពផ្សាយរបស់អ.វ.ត.ក "របាយការណ៍តុលាការ" ប្រចាំខែ មីនា ឆ្នាំ ២០១១ នៅទំព័រទី៦៖ "ពុំមានការស៊ើបអង្កេតអ្វីឡើយ ក្នុងខែ កុម្ភៈ"។ *ក៏សូមមើល* បោះពុម្ពផ្សាយរបស់អ.វ.ត.ក "របាយការណ៍តុលាការ" ប្រចាំខែ មេសា ឆ្នាំ ២០១១ នៅទំព័រទី៦

៨០. ដើម្បីឆ្លើយតបទៅនឹងសេចក្តីប្រកាសរបស់ ស.ច.ស ធ្វើឡើងនៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១១ បញ្ជាក់ពីការបិទការស៊ើបអង្កេតសំណុំរឿង ០០៣ នោះ សហព្រះរាជអាជ្ញាអន្តរជាតិ បានត្រួតពិនិត្យសំណុំរឿង ០០៣ ដោយអនុលោមតាមកាតព្វកិច្ចរបស់ខ្លួន ដូចមានចែងក្នុងវិធាន៦៦(៥) នៃវិធានផ្ទៃក្នុង[៧៣]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានសន្និដ្ឋានថា ការស៊ើបអង្កេតត្រូវបានបញ្ចប់ និងបានដាក់សំណើសុំឱ្យពន្យាពេលសម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[៧៤] និងសំណើស្នើឱ្យបើកកិច្ចស៊ើបសួរចំនួនបី[៧៥]។ នៅថ្ងៃ ៧ ខែ មិថុនា ឆ្នាំ ២០១១ ស.ច.ស បានចេញដីកាជំទាស់ បដិសេធសំណើនានា ដោយចាត់ទុកថាគ្មានសុពលភាព ដោយមិនបានវាយតម្លៃលើអង្គសេចក្តីរបស់សំណើទាំងនោះ ដោយគ្រាន់តែលើកឡើងថា លក្ខខណ្ឌតម្រូវជាផ្លូវការមិនត្រូវបានបំពេញ[៧៦]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់បណ្តឹងឧទ្ធរណ៍ ស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលសេចក្តីសម្រេចរបស់ ស.ច.ស និងដកស្រង់មូលហេតុមួយក្នុងចំណោមមូលហេតុនានា គឺការបំពារបំពានរបស់ ស.ច.ស ទៅលើ "កាតព្វកិច្ចផ្លូវច្បាប់របស់ខ្លួនក្នុងការបញ្ចប់ការស៊ើបអង្កេតដោយមិនលម្អៀង"[៧៧]។

៨១. ការខកខានមិនបានស៊ើបអង្កេតលើអង្គហេតុដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានរៀបរាប់នៅក្នុងពាក្យសុំរបស់ខ្លួន ឱ្យបានត្រឹមត្រូវ និងពេញលេញ ហើយដែល

---

ដែលពុំមានចែងសោះឡើយអំពីសកម្មភាពស៊ើបអង្កេតនៅតាមមូលដ្ឋាន។ គ្រប់ការបោះពុម្ពផ្សាយទាំងអស់នៅចន្លោះខែកុម្ភៈ និង ខែមេសា ចែងអំពីការពិនិត្យឡើងវិញនៅលើគុនូវរាល់សម្ភារៈនានា ដែលភាគច្រើនលើឯកសារក្នុងសំណុំរឿង០០២។

[៧៣] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹង "សេចក្តីសម្រេចលើសំណើសុំពន្យាពេល និងសំណើសុំស៊ើបអង្កេតរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទិននឹងសំណុំរឿង០០៣" កថាខណ្ឌ៤-៧ អាចមើលបាននៅ http://www.eccc.gov.kh/en/document/court/international-co-prosecutors-appeal-against-decisiontime-extension-request-and-inves.

[៧៤] ដូចជើងទំព័រខាងលើ។

[៧៥] ដូចជើងទំព័រខាងលើ។

[៧៦] ដូចជើងទំព័រខាងលើ។

[៧៧] សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបដិសេធសំណើនានាក្នុងសំណុំរឿង០០៣ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១១ អាចមើលបាននៅ៖
http://www.cambodiatribunal.org/sites/default/files/eccc%20ocp%2019%20aug%202011%20eng.pdf

សំខាន់ជាងនេះទៅទៀតនោះ ការខកខានមិនបានពិចារណាអង្គហេតុទាំងនេះ *ពាក់ព័ន្ធទៅនឹង* វិសាលភាពនៃការស៊ើបអង្កេតនោះ ស.ច.ស បានរំលោភបំពានលើកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

## ខ) ការជ្រៀតជ្រែកជាក់ស្តែងនៅក្នុងការសម្រេចតាមផ្លូវច្បាប់

៨២. ការស្នាក់ស្ទើររបស់ ស.ច.ស ក្នុងការស៊ើបអង្កេតឱ្យហួសពីសំណុំរឿង 00២ គឺមានប្រវត្តិតាំងពីយូរមកហើយ ហើយត្រូវការចោទប្រកាន់ថាកើតឡើងដោយសារតែមានការជ្រៀតជ្រែកពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាផ្នែកនយោបាយ[៧៨]។ គឺមានតែបុគ្គលិកអន្តរជាតិនៃការិយាល័យសហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ បានចូលរួមក្នុងការស៊ើបអង្កេតដល់ទីកន្លែងក្នុងសំណុំរឿង 00៣ និង/ឬ 00៤ បង្ហាញថា ការបែងចែករវាងសហព្រះរាជអាជ្ញាជាតិ/អន្តរជាតិ និងរវាង សហចៅក្រមស៊ើបអង្កេតជាតិ/អន្តរជាតិ គឺមានជាយូរមកហើយ។ បន្ថែមជាមួយនឹងការបិទកិច្ចស៊ើបសួរមុនកាលកំណត់សម្រាប់សំណុំរឿង 00៣ ដែលធ្វើឡើងនៅក្នុងខែមេសាទៀតនោះ ព្រឹត្តិការណ៍នេះបានធ្វើឱ្យមានសំណួរជាច្រើន ដូចជា "ថាតើការស៊ើបអង្កេតនៅនឹងតុធ្វើការ ត្រូវបានរៀបចំឡើង ដើម្បីផ្តល់នូវការបិទបាំងតាមផ្លូវច្បាប់សម្រាប់ការច្រានចោល ក្រោមការកំណត់របស់នយោបាយ នៃសំណុំរឿងសំណុំរឿងនានាដែលផ្ទុយនឹងឆន្ទៈនយោបាយ"[៧៩]។

---

[៧៨] "នេះគឺស្របគ្នានឹងផែនការដែលបានរាយការណ៍ដោយចៅក្រម ក្នុងការចាត់ចែងនឹងសំណុំរឿងទាំងពីរ ដែលកំពុងស្ថិតនៅចំពោះមុខតុលាការ ដែលសំណុំរឿងទាំងពីរនេះមានពាក់ព័ន្ធនឹងជនរងគ្រោះច្រើនជាង១00.000នាក់។ ពុំមានការចាប់ខ្លួនជនណាម្នាក់ និងប្រកាសបទចោទអ្វីមួយឡើយ" ក្នុងអត្ថបទមួយក្រោមចំណងជើងថា "ការបិទសំណុំរឿងអាចឆ្លុះបញ្ចាំងអំពីមតិយោបល់ជាផ្លូវការរបស់ពួកខ្មែរក្រហម" *The Cambodia Daily* ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២0១១ ទំព័រមុខ ដោយ Douglas Gillison។

[៧៩] របាយការណ៍ OSJI "ការវិវឌ្ឍថ្មីៗនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ខែ មិថុនា ឆ្នាំ ២0១១។ អាចមើលបាននៅ៖

http://www.soros.org/initiatives/justice/articles_publications/publications/cambodia-eccc-20110614/cambodia-eccc-20110614.pdf

៨៣. "ការស៊ើបអង្កេត" របស់ ស.ច.ស ត្រូវជួបបញ្ហាតាំងពីខាងដើម តាមរយៈ "ការមិនព្រមចុះហត្ថលេខា" លើដីកាចាត់ឱ្យស៊ើបសួរជំនួស ក្នុងសំណុំរឿង ០០៣ និង ០០៤ របស់ លោកចៅក្រមជាតិ យូ ប៊ុនឡេង[៨០]។ នៅថ្ងៃទី ៤ ខែ មិថុនា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់កាលបរិច្ឆេទកំណត់ ដើម្បីឱ្យសហចៅក្រមស៊ើបអង្កេតជាតិជាដៃគូ ចុះហត្ថលេខាលើដីកាចាត់ឱ្យស៊ើបសួរជំនួស ត្រឹមថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១០។ ប៉ុន្តែ សកម្មភាពស៊ើបអង្កេតលើកដំបូងនានា នៅក្នុងសំណុំរឿង ០០៣ និង ០០៤ ត្រូវបានរាយការណ៍ថាត្រូវបានប្រព្រឹត្តទៅកាលពីថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១០ តាមដីកាចាត់ឱ្យស៊ើបសួរជំនួសសម្ងាត់ ដែលត្រូវបានចុះហត្ថលេខាដោយ ស.ច.ស *ទាំងពីរ*[៨១]។

៨៤. បន្ទាប់ពីនោះគឺមានចម្លើយតប ភ្លាមៗមួយ៖ "អ្នកនាំពាក្យក្រសួងមហាផ្ទៃ [នៃរាជរដ្ឋាភិបាលកម្ពុជា] ឧត្តមសេនីយ៍ឯក ខៀវ សុភ័គ្រ បានបញ្ជាក់ឡើងវិញនូវការជំទាស់ [របស់រាជរដ្ឋាភិបាលកម្ពុជា] ចំពោះការស៊ើបអង្កេតថ្មីៗ [...]" ដោយលោកបានដកស្រង់នូវការព្រមានរបស់សម្តេច ហ៊ុន សែន ពីភាពវឹកវរ។ "មានការកាត់ទោសមេដឹកនាំកំពូលៗតែប្រាំរូបប៉ុណ្ណោះ។ មិនមែនប្រាំមួយនាក់ទេ គឺប្រាំនាក់ប៉ុណ្ណោះ។ តុលាការត្រូវតែធានានូវស្ថិរភាព និងសន្តិភាពនៅក្នុងប្រទេស។ យើងមិនចង់បានជម្លោះ និងអស្ថិរភាពផ្ទៃក្នុងនោះឡើយ"[៨២]។

៨៥. នៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០ បន្ទាប់ពីបានចុះហត្ថលេខារួចហើយ លោកចៅក្រម យូ ប៊ុនឡេង បានជូនដំណឹងដល់ភាគីអន្តរជាតិជាដៃគូថា "នៅមិនទាន់ដល់ *ពេលវេលា* ដើម្បីចាត់

---

[៨០] អនុស្សរណៈផ្ទៃក្នុងរបស់ក.ស.ច.ស ពីចៅក្រម យូ ប៊ុនឡេង ផ្ញើជូន ចៅក្រម Marcel Lemonde នៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០ "Dossiers 003 et 004" (ការបកប្រែក្រៅផ្លូវការពីភាសាបារាំងមកភាសាអង់គ្លេស)

[៨១] Douglas Gillison 'សាលាក្តីខ្មែរក្រហមចាប់ផ្តើមស៊ើបអង្កេតជនសង្ស័យថ្មី៥នាក់ទៀត' *The Cambodia Daily* ចុះផ្សាយថ្ងៃទី៨ ខែ មិថុនា ឆ្នាំ ២០១០ ទំព័រ២៦ (គូសបញ្ជាក់បន្ថែម)។ រាជ សម្បត្តិ មន្ត្រីអ្នកនាំពាក្យរបស់តុលាការបានចេញនូវសេចក្តីប្រកាសព័ត៌មានមួយអំពីការដកខ្លួនរបស់ចៅក្រម យូ ប៊ុនឡេង ពីដីកាចាត់ឱ្យស៊ើបសួរជំនួស និងថ្លែងថាសេចក្តីរាយការណ៍"ព័ត៌មាន" ស្តីពីការចុះហត្ថលេខាលើឯកសារ គឺពឹងផ្អែកទៅលើព័ត៌មានដែលបានផ្តល់ដោយលោក Lars Olsen មន្ត្រីទំនាក់ទំនងផ្នែកច្បាប់អន្តរជាតិ ដែលជាព័ត៌មានដែលគ្មានមូលដ្ឋានច្បាស់លាស់។

[៨២] ដូចដើងទំព័រខាងលើ។

ការសំណុំរឿង ០០៣ និង ០០៤ នោះទេ" [៨៣]។ នៅខែមិថុនា ឆ្នាំ២០១០ អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌នៃវិទ្យាស្ថានសង្គមសេរី (OSJI) ដែលជាអ្នកឃ្លាំមើលសាលាក្តីដ៏មានកេរ្តិ៍ឈ្មោះមួយបានចេញនូវរបាយការណ៍មួយដែលវាយតម្លៃលើការ "មិនចុះហត្ថលេខា"នេះដូចខាងក្រោម៖

> លោកចៅក្រម យូ ប៊ុនឡេង ជាដំបូងបានចុះហត្ថលេខាអនុញ្ញាតឱ្យមានការស៊ើបអង្កេតទាំងនេះ ប៉ុន្តែក្រោយមកបន្តិចបានលប់ចោលការយល់ព្រមរបស់លោក បន្ទាប់ពីដីកានេះត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយអ្នកនាំពាក្យក្រសួងមហាផ្ទៃបានបញ្ជាក់សារជាថ្មីជាសាធារណៈថា "មានតែមេដឹកនាំកំពូលចំនួនប្រាំរូបប៉ុណ្ណោះត្រូវទទួលការកាត់ទោស"។ លោកចៅក្រម យូ ប៊ុនឡេង បានលើកយក "ស្ថានភាពបច្ចុប្បន្ននៃសង្គមកម្ពុជា" មកធ្វើជាមូលហេតុសម្រាប់ការច្រានចោលនូវការយល់ព្រមចំពោះការស៊ើបអង្កេតណាមួយទៅលើសំណុំរឿង។ លោកបានចង្អុលបង្ហាញថា ការស៊ើបអង្កេតទៅលើសំណុំរឿងណាមួយ នឹងត្រូវពិចារណាម្តងទៀតបន្ទាប់ពីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ [សម្រាប់សំណុំរឿង០០២]។ **ទាំងនេះគឺជាសនិទានកម្មផ្នែកនយោបាយយ៉ាងជាក់ច្បាស់។**
>
> នៅពេលដែលគិតដល់ការជំទាស់ជារៀងរហូតមករបស់រាជរដ្ឋាភិបាល ដែលមិនអនុញ្ញាតឱ្យមានការបន្តសំណុំរឿង០០៣ និង០០៤ ទៅមុខដោយឯករាជ្យនោះ ចំណុចនេះវាគាំទ្រដល់ការសន្និដ្ឋានដែលថា ការជ្រៀតជ្រែកផ្នែកនយោបាយ ធ្វើឱ្យប៉ះពាល់យ៉ាងអាក្រក់ដល់សេចក្តីសម្រេចចំពោះសំណុំរឿង [៨៤]។

៨៦. នៅថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់ពីការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតទាំងពីរ "ពាក់ព័ន្ធនឹងបញ្ហាពេលវេលាសមស្របសម្រាប់ចំណាត់ការស៊ើបសួរ" និងថា "សម្រាប់រយៈពេលរហូតដល់ដំណាច់ឆ្នាំនេះ សហ

---

[៨៣] អនុស្សរណៈផ្ទៃក្នុងរបស់ក.ស.ច.ស ពីចៅក្រម យូ ប៊ុនឡេង ផ្ញើជូន ចៅក្រម Marcel Lemonde នៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០ "Dossiers 003 et 004" (ការបកប្រែក្រៅផ្លូវការពីភាសាបារាំងមកភាសាអង់គ្លេស)

[៨៤] អង្គការ OSJI "ការជ្រៀតជ្រែកផ្នែកនយោបាយនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ចុះខែ កក្កដា ឆ្នាំ ២០១០ អាចមើលបាននៅ http://www.soros.org/initiatives/justice/focus/international_justice/articles_publications/publications/political-interference-report-20100706 ទំព័រទី២១ (គូសបញ្ជាក់បន្ថែម)។

ចៅក្រមស៊ើបអង្កេតអន្តរជាតិនឹងបន្តដំណើរការងារនេះតែម្នាក់ឯង ដោយអនុលោមទៅតាមបញ្ញត្តិនៃវិធាន ៧២ នៃវិធានផ្ទៃក្នុង អ.វ.ត.ក"[៨៥]។ អ្នកតាមឃ្លាំមើលបានយល់ឃើញថា "ការខ្វែងយោបល់គ្នានេះគឺស្រុបជាមួយនឹងការបង្ហាញជាចំហរចំពោះការស្នាក់ស្ទើររបស់រាជរដ្ឋាភិបាល ក្នុងការចោទប្រកាន់ទៅលើមេដឹកនាំនៃរបបខ្មែរក្រហមថ្មីបន្ថែម ពីលើមេដឹកនាំទាំងប្រាំនាក់ដែល[ស្ថិតក្នុងការឃុំឃាំង] រួចហើយ"[៨៦]។ ហើយ "ក្នុងពេលឥឡូវនេះលោកចៅក្រម Marcel Lemonde បានបន្តដំណើរការងារនេះដោយគ្មានការគាំទ្រពីសហការីជាតិរបស់គាត់ ក្នុងការស៊ើបអង្កេតទៅលើបទចោទដែលមានលក្ខណៈនយោបាយ ហើយដែលមន្ត្រីរាជរដ្ឋាភិបាលបានបញ្ជាក់រួចមកហើយថាមិនត្រូវបន្តទៅមុខឡើយ"[៨៧]។

៨៧. លទ្ធផលនៃការខកខានមិនធ្វើការស៊ើបអង្កេតឱ្យបានពេញលេញ ឬត្រឹមត្រូវនោះ វាហាក់ដូចជាជាប់ទាក់ទិនទៅនឹងសេចក្តីថ្លែងការណ៍ជាសាធារណៈដដែលៗរបស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន**[៨៨]។ រដ្ឋមន្ត្រីក្រសួងការបរទេស ឯកឧត្តម **ហោ ណាំហុង** បានប្រាប់អ្នកយកព័ត៌មានបន្ទាប់ពីមានជំនួបរវាងលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ជាមួយសម្តេចនាយករដ្ឋមន្ត្រីថា "យើងត្រូវតែគិតអំពីសន្តិភាពនៅកម្ពុជា"[៨៩]។ អង្គការ OSJI បានវាយតម្លៃទៅលើសេចក្តីថ្លែងការក្នុងពេលថ្មីៗនេះដូចខាងក្រោម៖

---

[៨៥] សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត អាចមើលបាននៅ៖ http://old.eccc.gov.kh/english/cabinet/press/156/PROCIJ%28JUne2010.pdf

[៨៦] Sebastian Strangio 'ចៅក្រមតុលាការខ្មែរក្រហមមានទស្សនៈផ្ទុយគ្នាលើសំណុំរឿងបន្ទាប់' កាសែត *The Phnom Penh Post* ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ ទំព័រទី១។

[៨៧] Douglas Gillison 'សំណួរច្រើនជាងចម្លើយ' *The Cambodia Daily* ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០។

[៨៨] រាប់បញ្ចូលនូវមតិយោបល់ជូនដល់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ Ban Ki-moon ដែលបានមកទស្សនានៅខែ តុលា ឆ្នាំ ២០១០ ថា "ការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមទីពីររបស់ពួកខ្មែរក្រហម ដែលនឹងចាប់ផ្តើមនៅដើមឆ្នាំក្រោយនេះ គឺជាការជំនុំជម្រះចុងក្រោយ។ លោក ហ៊ុន សែន បានគូសបញ្ជាក់យ៉ាងច្បាស់ថា សំណុំរឿងលេខបី នឹងមិនអនុញ្ញាតឱ្យមានឡើយ"។

[៨៩] របាយការណ៍របស់ AFP 'នាយករដ្ឋមន្ត្រីកម្ពុជាព្រមានថា នឹងគ្មានការជំនុំជម្រះសំណុំរឿងទីបីចំពោះពួកខ្មែរក្រហមឡើយ" ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១០។ របាយការណ៍ OSJI ស្តីពី 'Salvaging Justice' ដែលអាចមើលបាននៅ

ការជ្រៀតជ្រែកផ្នែកនយោបាយទៅក្នុងកិច្ចការរបស់តុលាការ យ៉ាងឥតលាក់លៀមបែបនេះ គឺពិតជាផ្ទុយទៅនឹងបទដ្ឋានជាមូលដ្ឋាននៃជំនុំជម្រះដោយយុត្តិធម៌[៥០] ហើយ

ជាក់ស្តែង មន្ត្រីតុលាការកម្ពុជាមិនមានសេរីភាពក្នុងការដំណើរការនីតិវិធីដោយឯករាជ្យ ចំពោះការចោទប្រកាន់ដែលត្រូវទទួលរងការជំទាស់ជាចំហរ និងជាប្រចាំពីសំណាក់ [នាយករដ្ឋមន្ត្រី] បែបនេះឡើយ។ ជាការគួរឱ្យយល់បានថា មន្ត្រីតុលាការកម្ពុជាពិតជាភ័យខ្លាចមិនហ៊ានរឹងទទឹងជាចំហរ ប្រឆាំងនឹងបញ្ហាជាសាធារណៈរបស់ប្រមុខរដ្ឋនោះឡើយ[៥១]។

៨៨. ការណែនាំជាក់ស្តែង ឬអាចបាននឹង ដែលបញ្ជាក់ថា ស.ច.ស ទទួលយកឥទ្ធិពលនយោបាយនោះ បណ្តាលឱ្យមានការរំលោភបំពានទៅលើបញ្ញត្តិពាក់ព័ន្ធនានា នៃកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ដែលស្តីអំពីតួនាទីរបស់ចៅក្រមនៅក្នុងអង្គជំនុំជម្រះ ព្រមទាំងអាកប្បកិរិយា ដែលចៅក្រមត្រូវប្រកាន់ខ្ជាប់ក្នុងការបំពេញតួនាទីទាំងនេះ។

### គ) ការខកខានមិនបានបំពេញតួនាទី មុខងារ និងភារកិច្ចតាមផ្លូវច្បាប់ អនុលោមតាមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

---

http://www.soros.org/initiatives/justice/focus/international_justice/articles_publications/publications/khmer-rouge-tribunal-20101110.

[៥០] របាយការណ៍របស់ OSJI 'Salvaging Judicial Independence: តម្រូវការឱ្យមានផែនការបញ្ចប់តាមគោលការណ៍មួយ សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" អាចមើលបាននៅ៖ http://www.soros.org/initiatives/justice/focus/international_justice/articles_publications/publications/khmer-rouge-tribunal-2010។ របាយការណ៍ OSJI 'ការវិវឌ្ឍថ្មីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ប្រចាំខែធ្នូ ឆ្នាំ ២០១០ អាចរកមើលបាននៅ៖ http://www.soros.org/initiatives/justice/focus/international_justice/articles_publications/publications/cambodia-report-20101207/cambodia-khmer-rouge-report-20101207.pdf.110.

[៥១] របាយការណ៍ OSJI 'ការវិវឌ្ឍថ្មីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ប្រចាំខែធ្នូ ឆ្នាំ ២០១០ អាចរកមើលបាននៅ៖ http://www.soros.org/initiatives/justice/focus/international_justice/articles_publications/publications/cambodia-report-20101207/cambodia-khmer-rouge-report-20101207.pdf.

៨៩. សហចៅក្រមស៊ើបអង្កេត មិនបានបំពេញតួនាទី ភារកិច្ច និងមុខងារផ្នែកច្បាប់របស់ខ្លួនស្របតាមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលចែងថា៖

"រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ... ដែលហៅថា "សហចៅក្រមស៊ើបអង្កេត" ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន ... សហចៅក្រមស៊ើបអង្កេតមានអំណាច ក្នុងការសួរចម្លើយជនសង្ស័យ ការស្តាប់ចម្លើយជនរងគ្រោះ និងស្តាប់ចម្លើយសាក្សី និងប្រមូលភស្តុតាងដោយអនុវត្តតាមនីតិវិធីជាធរមាន..."[៩២]។

៩០. ស.ច.ស មិនបានធ្វើតាម "នីតិវិធីជាធរមាន" ដែលរួមមានការសួរយកចម្លើយជនសង្ស័យ និងជនរងគ្រោះ ការស្តាប់ចម្លើយសាក្សី និងការប្រមូលភស្តុតាងនោះឡើយ។ សហចៅក្រមស៊ើបអង្កេតមិនបានដំណើរការកិច្ចស៊ើបសួរថ្មីនៅក្នុងសំណុំរឿង០០៣ ឡើយ ហើយ ស.ច.ស បានយោងតែទៅលើឯកសារសម្ភារៈដែលមានស្រាប់នៅក្នុងសំណុំរឿង០០១ និង០០២ ប៉ុណ្ណោះ។

៩១. ដោយសារ សំណុំរឿង០០១ និង០០២ ទាក់ទិននឹងជនសង្ស័យប្រាំនាក់ផ្សេងទៀតទាំងស្រុង ដែលមានតួនាទី និងមុខងារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យផ្សេងៗគ្នានោះ វិធីសាស្ត្ររបស់ ស.ច.ស ក្នុងការស៊ើបអង្កេតនេះ គឺជាការមិនសមហេតុផល និងស្របតាមជំនាញនោះទេ។ វិធីសាស្ត្រនេះបង្ហាញនូវឃើញពីអវត្តមាននូវគំនិតផ្តួចផ្តើម ឆន្ទៈ ឬការជម្រុញណាមួយដល់ការអនុវត្តនូវមុខងាររបស់ខ្លួនឱ្យបានពេញលេញ ត្រឹមត្រូវ និងឯករាជ្យ។

៩២. ឧទាហរណ៍ពាក់ព័ន្ធមួយទៀតអំពីការជ្រៀតជ្រែកដោយផ្ទាល់ពីសំណាក់រាជរដ្ឋាភិបាលទៅក្នុងកិច្ចការរបស់តុលាការ ក្នុងសំណុំរឿង០០២ គឺនៅពេលដែល ក.ស.ច.ស មិនអាចធ្វើការស្តាប់ចម្លើយសាក្សីសំខាន់ៗដែលបានទទួលការបង្គាប់បញ្ជាមិនឱ្យគោរពតាមដីកាកោះហៅរបស់តុលាការនោះ។ ក្រោយពីមានបណ្តឹងឧទ្ធរណ៍ពីសំណាក់មេធាវីការពារក្តី[៩៣] ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានថ្លែងថា "បើទោះបីជា ក.ស.ច.ស ស្ថាប័នស៊ើបអង្កេតរបស់

[92] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (NS/RKM/1004/006, មាត្រា២៣ ទំព័រ៩។

[៩៣] សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោកអៀង សារី និងលោកនួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់កសចស លើសំណើសុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D314/1/12 ទំព័រ២១។

អ.វ.ត.កក៏ដោយ តែ ក.ស.ច.ស បានបដិសេធជាច្រើនលើកច្រើនសារ មិនធ្វើការស៊ើបអង្កេតទៅលើបញ្ហានេះទេ [ការចោទប្រកាន់ពីការជ្រៀតជ្រែក]"។ ចៅក្រមអន្តរជាតិយល់ឃើញថា "យោបល់របស់ ខៀវ កញ្ញារិទ្ធធ្វើឱ្យយើងជឿថា មានហេតុផលគួរឱ្យជឿថាគាត់ ឬបុគ្គលដែលគាត់និយាយដោយជំនួសមុខឱ្យនោះ អាចប៉ុនប៉ងដោយចេតនាពិតប្រាកដ ក្នុងការគម្រាមកំហែង ឬបំភិតបំភ័យមន្ត្រីទាំង៦រូប ឬបើមិនដូច្នោះទេ ជ្រៀតជ្រែកលើការសម្រេចចិត្តរបស់មន្ត្រីទាំង៦រូបនោះ ទាក់ទងនឹងការអញ្ជើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឱ្យមកផ្តល់សក្ខីកម្ម"[៩៤]។

៩៣. ចៅក្រមកម្ពុជាម្នាក់រូបនៅ អ.វ.ត.ក បានប្រាប់លោក James Goldston ដែលជានាយកប្រតិបត្តិនៃអង្គការ OSJI កាលពីដើមខែ កុម្ភៈ ឆ្នាំ ២០១០ ថា អ្វីដែលសំខាន់នោះគឺថា "តើយើងអាចធ្វើឱ្យតុលាការនេះជាតុលាការគំរូនៃយុត្តិធម៌ឯករាជ្យបានដោយរបៀបណា បើរដ្ឋាភិបាលមិនអនុញ្ញាតឱ្យយើងបំពេញការងាររបស់យើងបានផងនោះ?"[៩៥]។

៩៤. លើសពីនេះទៀត នៅក្នុងសេចក្តីថ្លែងការណ៍មួយ ធ្វើនៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១១ OSJI បានសម្តែងឱ្យឃើញនូវការព្រួយបារម្ភរបស់ខ្លួន ពាក់ព័ន្ធទៅនឹងការបដិសេធអ្នកដាក់ពាក្យសុំ តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយស្រដៀងគ្នានេះ ព្រមទាំងការវិវឌ្ឍផ្សេងៗទៀតដែល បានចូលរួមចំណែកបន្ថែមទៀតជាមួយនឹងភស្តុតាងដែលមានទំហំច្រើនគួរសមរួចទៅហើយនោះ បង្កើតបានជាសំនួរសំខាន់ៗនានា ពាក់ព័ន្ធទៅនឹង ឯករាជ្យភាព សមត្ថភាព និងវិជ្ជាជីវៈ របស់សហចៅក្រមស៊ើបអង្កេតទាំងពីររូប នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ អង្គការសហប្រជាជាតិបានអំពាវនាវជាថ្មីម្តងទៀត នូវអ្វីដែលធ្លាប់បានអំពាវនាវរួចមកហើយ កាលពីខែមិថុនា ឆ្នាំ២០១១ ដោយលើកឡើងថា "ស៊ើបអង្កេតដោយឯករាជ្យ

---

[៩៤] ដូចជើងទំព័រខាងលើ។

[៩៥] James Goldston 'តុលាការរបស់កម្ពុជាកំពុងស្ថិតក្នុងផ្លូវបំបែក' *Wall Street Journal* ចុះថ្ងៃទី១ ខែ មីនា ឆ្នាំ ២០១០

នូវការចោទការប្រកាន់ធ្ងន់ធ្ងរនានា ហើយសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានចេតនារារាំងដល់ការស៊ើបអង្កេត"[៩៦]។

### ឃ) ការយល់ឃើញទុកជាមុនដោយប្រើយុត្តាធិការផ្ទាល់ខ្លួន គឺលម្អៀងក្នុងការកំណត់ដើមបណ្តឹងរដ្ឋប្បវេណី

៩៥. នៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួន ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១១ ស.ច.ស បានថ្លែងថា ស.ច.ស មាន "ការសង្ស័យយ៉ាងខ្លាំង" ចំពោះ ថាតើជនសង្ស័យនានានៅក្នុងសំណុំរឿង ០០៤ (និងជនសង្ស័យទាំងឡាយ ដែលរងការចោទប្រកាន់រួចជាស្រេចនៅក្នុងសំណុំរឿង ០០៣ នោះ) អាចនឹងត្រូវចាត់ទុកជា "បុគ្គលទទួលខុសត្រូវខ្ពស់បំផុត" ដែរឬយ៉ាងណា អនុលោមតាមលក្ខខណ្ឌតម្រូវយុត្តាធិការរបស់តុលាការនោះ[៩៧]។ បន្ទាប់មក នៅថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១១ ស.ច.ស បានដាក់ចេញនូវសេចក្តីសម្រេចរបស់ខ្លួន ពាក់ព័ន្ធនឹងភាពអាចទទួលយកបានរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍[៩៨]។

៩៦. កាលបរិច្ឆេទសេចក្តីសម្រេចរបស់ ស.ច.ស គឺជាក់ស្តែងធ្វើឡើងដោយគិតដល់ពេលវេលាក្រោយធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួន ដោយសារ ស.ច.ស បានបញ្ជាក់ថា មូលហេតុសម្រាប់ការបដិសេធនោះ គឺមិនមែនតាមរយៈការពិចារណាឲ្យបានត្រឹមត្រូវទៅលើពាក្យបណ្តឹងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ទៅនឹងលក្ខណៈសម្បត្តិនៃភាពអាចទទួលយកបានតាមផ្លូវច្បាប់ នោះទេ គឺដោយសារតួនាទីក្នុងការកំណត់ទុកជាមុន អំពីយុត្តាធិការផ្ទាល់ខ្លួនរបស់តុលាការទៅវិញ។

---

[៩៦] សេចក្តីប្រកាសព័ត៌មានរបស់ OSJI "តុលាការខ្មែរក្រហមរបស់កម្ពុជាផាត់ចោលសំឡេងរបស់ជនរងគ្រោះ" អាចមើលបាននៅ http://www.soros.org/initiatives/justice/news/cambodia-victims-20110916

[៩៧] សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៤ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១១ អាចមើលបាននៅ http://www.cambodiatribunal.org/sites/default/files/ECCC%20PR%20OCIJ%208%20Aug%202011%20%28Eng%29.pdf

[៩៨] ក.ស.ច.ស "ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted]" ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ D11/4/3។

00746436



ទង្វើនេះ ក៏ហាក់ដូចជាមានផលប៉ះពាល់ជាក់ស្តែងទៅលើវិធីសាស្ត្រ ដែល ស.ច.ស បានដាក់ចេញដើម្បីអនុវត្តកាតព្វកិច្ចស៊ើបអង្កេតរបស់ខ្លួនផងដែរ[៩៩]។

៩៧. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងថា ការកំណត់បែបនេះ ត្រូវបានធ្វើឡើងជាមុន និងធ្វើឱ្យប៉ះពាល់ដោយមិនសមហេតុផលដល់ការកំណត់ដ៏ត្រឹមត្រូវទៅលើភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០៣។ នៅក្នុងសំណុំរឿង ០០១ កាំង ហ្កេកអ៊ាវ ត្រូវបាន*អង្គជំនុំជម្រះសាលាដំបូង* រកឃើញថា ស្ថិតនៅក្នុងប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ហេតុដូច្នេះហើយ ត្រូវស្ថិតនៅក្នុងយុត្តាធិការផ្ទាល់របស់អង្គជំនុំជម្រះ[១០០]។ ប្រសិនបើទុកឱ្យអង្គជំនុំជម្រះសាលាដំបូង កំណត់នូវចំណុចផ្លូវច្បាប់នេះ ហើយ លក្ខណៈសម្បត្តិដែលអង្គជំនុំជម្រះសាលាដំបូង បានយកមកប្រើនៅក្នុងសំណុំរឿង ០០១ ត្រូវ យកមកអនុវត្តនោះម្តងទៀតនោះ លទ្ធផលគឺនឹងត្រូវរកឃើញថា [redacted] ក៏ជាបុគ្គលម្នាក់ ដែលនឹងត្រូវស្ថិតនៅក្រោមយុត្តាធិការ ផ្ទាល់ របស់តុលាការផងដែរ។ យោងតាមការអះអាងរបស់ការិយាល័យសហព្រះរាជអាជ្ញា [redacted] គឺជាបុគ្គលដែលមានឥទ្ធិពលម្នាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង [redacted][១០១]។ ហេតុដូច្នេះហើយ អាចនិយាយបានថា តួនាទីរបស់ [redacted] គឺអាចនឹងស្ថិតនៅក្នុង លំដាប់មួយដែលខ្ពស់ជាងតួនាទីរបស់ កាំង ហ្កេកអ៊ាវទៅទៀត [redacted][១០២]។

---

[៩៩] Tatiana Sainati "វិសាលភាពនៃករណីយកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការស៊ើបសួរ" *DC-CAM* ទំព័រ៣៤-៣៧។

[១០០] សំណុំរឿងប្រឆាំងនឹង កាំង ហ្កេកអ៊ាវ 001-18-07-2007-ECCC/TC សាលក្រម ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០។

[១០១] [redacted]

[១០២] [redacted]

៩៨. សេចក្តីថ្លែងការណ៍ ស្តីអំពី "ការព្រួយបារម្ភធ្ងន់ធ្ងរ" របស់ ស.ច.ស សម្តែងឱ្យឃើញនូវភាពគ្មានឆន្ទៈរបស់ខ្លួន ក្នុងការស៊ើបអង្កេតសំណុំរឿង ០០៣ ឱ្យបានត្រឹមត្រូវ ហើយបង្ហាញថា ស.ច.ស នឹងសម្រេចច្រានចោលសំណុំរឿង នៅពេលស.ច.ស ដាក់ចេញដីកាដំណោះស្រាយដែលជាចុងក្រោយនិងធ្វើឱ្យមានភាពសៅហ្មង និងលម្អៀងចំពោះសេចក្តី សម្រេចនានាលើភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី[១០៣]។

៩៩. ជាសរុប ការមិនបានធ្វើការស៊ើបអង្កេតដោយឯករាជ្យ ឱ្យបានដិតដល់ និងមិនពាក់ព័ន្ធជាមួយនឹងការហាមប្រាមរបស់ នាយករដ្ឋមន្ត្រី ក្នុងការស៊ើបអង្កេតសំណុំរឿង ០០៣នោះ មានន័យថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ត្រូវបានបដិសេធ ដោយមិនបានធ្វើការស៊ើបអង្កេត។ យើងសូមស្នើថា ដីកាបដិសេធនេះ មានកំហុសផ្នែកច្បាប់ និងរំលោភបំពានវិធាន១៤(១) វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង និងមាត្រា១០ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា៥(២៩ និង(៣) នៃកិច្ចព្រមព្រៀង និងគោលការណ៍ប្រឆាំងនិទណ្ឌភាពរបស់អង្គការសហប្រជាជាតិ។ ជាមួយនឹងរាល់សំអាងហេតុទាំងនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍ទាមទារបដិសេធចោលនូវសេចក្តីសម្រេចរបស់ ស.ច.ស ដែលបានចាត់ទុកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន មិនអាចទទួលយកបាន។

## ៦. មូលដ្ឋានទីប្រាំមួយនៃបណ្តឹងឧទ្ធរណ៍

*"តាមរយៈការច្រានចោលបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ស.ច.ស បានរារាំងដល់កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក តាមរយៈការបណ្តោយឱ្យ និទណ្ឌភាពល្មើស ហើយទង្វើបែបនេះ គឺជាការប្រព្រឹត្តផ្ទុយទៅនឹងគោលដៅជាចម្បងរបស់ អ.វ.ត.ក ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក"*

១០០. ចក្ខុវិស័យសម្រាប់ អ.វ.ត.ក ដែលនឹងត្រូវក្លាយទៅជា "តុលាការថ្មីដ៏ពិសេស" "ឯករាជ្យ" មួយ ទាំងរបស់រដ្ឋាភិបាល និងអង្គការសហប្រជាជាតិនោះ បានចែងថា៖

[១០៣] Tatiana Sainati "វិសាលភាពនៃករណីយកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការស៊ើបសួរ" *DC-CAM* ទំព័រ២៧។

00746438



"តុលាការនេះ គឺជាតុលាការកម្ពុជា ដែលមានការចូលរួមពី សហគមន៍អន្តរជាតិ ដែលនឹងអនុវត្ត ទៅតាមស្តង់ដារអន្តរជាតិ ។ តុលាការនេះ នឹងផ្តល់ជាគំរូតួនាទីថ្មីមួយសម្រាប់ ដំណើរការកាត់ក្តីនៅកម្ពុជា"[១០៤] ។

ប៉ុន្តែ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងថា បទដ្ឋាន ដែល ស.ច.ស បានរៀបចំឡើងនៅក្នុងសំណុំរឿង០០៣ គឺធ្វើឡើងដោយមិនមានការស៊ើបអង្កេត មិនបានបំពេញតាមតួនាទីរបស់ខ្លួនដោយទទួលឥទ្ធិពលពីនយោបាយ គ្មានតម្លាភាព ប្រព្រឹត្តមិនបានត្រឹមត្រូវទៅលើជនរងគ្រោះ និងបដិសេធមិនឱ្យមានការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណី ដោយទង្វើទាំងអស់នេះ ធ្វើឱ្យរាំងស្ទះដល់ដំណើរការស្វែងរកយុត្តិធម៌របស់ អ.វ.ត.ក ជម្រុញឱ្យមាននិទណ្ឌភាព និងរំលោភបំពានបទដ្ឋានអន្តរជាតិដ៏ត្រឹមត្រូវ ព្រមទាំងរំលោភបំពានសិទ្ធនានារបស់ជនរងគ្រោះ។

១០១. ការបដិសេធរបស់ ស.ច.ស ទៅលើសិទ្ធក្នុងការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ នៅក្នុងសំណុំរឿង ដែលគាត់គឺជា "ជនរងគ្រោះ" មួយរូប ស្ថិតក្រោមការចែងដ៏ត្រឹមត្រូវ នៅក្នុងសេចក្តីណែនាំអនុវត្ត និងវិធានផ្ទៃក្នុង នោះ បណ្តាលឱ្យមានការសង្ស័យដ៏ស្រួចស្រាវមួយ នោះគឺ ស.ច.ស បានព្យាយាមរក*គ្រប់* មូលហេតុ ដើម្បីបដិសេធបណ្តឹងរដ្ឋប្បវេណីដ៏មុតមាំ និងជំនះខ្លាំងបំផុតរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ នៅក្នុងសំណុំរឿង០០៣ ដោយសារតែមានការជ្រៀតជ្រែកផ្នែកនយោបាយ។

១០២. សេចក្តីថ្លែងការណ៍របស់ ស.ច.ស ដែលបានលើកឡើងថា [redacted] មិនមែនជាបុគ្គលមួយដែលស្ថិតនៅក្រោមយុត្តាធិការផ្ទាល់របស់អង្គជំនុំជម្រះនោះ គឺជាការចង្អុលបង្ហាញជាសាធារណៈមួយថា ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺត្រូវធ្វើឡើង ហើយបន្ទាប់មកនឹងមានការបោះបង់ចោលសំណុំរឿង ០០៣ ដែលនឹងធ្វើឡើងដោយ ស.ច.ស។ ការលើកឡើងនេះត្រូវបានគាំទ្រដោយព្រឹត្តិការណ៍អកុសលមួយនាដើមឆ្នាំ ២០១១ នៅពេលដែលអ្នកស៊ើបអង្កេត

---

[១០៤] សូមមើលគេហទំព័រជាផ្លូវការរបស់អ.វ.ត.ក http://www.eccc.gov.kh/en/about-eccc/introduction, នៅថ្ងៃទី១១ ខែ ឧសភា ឆ្នាំ ២០១១។ គូសបញ្ជាក់បន្ថែម

00746439



អង្គការសហប្រជាជាតិ ត្រូវបានជូនដំណឹងថា កិច្ចសន្យាការងាររបស់ពួកគេ មិនត្រូវបានបន្តឱ្យហួសចុងឆ្នាំនេះនោះទេ[១០៥]។

១០៣. ការមិនផ្តល់ព័ត៌មានជាសាធារណៈណាមួយអំពីវិសាលភាព ក៏ដូចជាលក្ខណៈនៃសំណុំរឿង 00៣ និង00៤ ព្រមទាំងការថ្កោលទោសចំពោះសហព្រះរាជអាជ្ញាអន្តរជាតិដែលបំពេញមុខងាររបស់ខ្លួនតាមវិធាន៥៤ នៃវិធានផ្ទៃក្នុងក្នុងការផ្សព្វផ្សាយព័ត៌មានដល់សាធារណជននោះ គឺមានន័យថា សហចៅក្រមស៊ើបអង្កេតបានរារាំងដោយមានប្រសិទ្ធភាពចំពោះដំណើរការស្វែងរកយុត្តិធម៌ ដែលខ្លួនត្រូវដើរតួនាទីយ៉ាងសំខាន់ និងមានប្រសិទ្ធភាព។

១០៤. ឥទ្ធិពល និងផលប៉ះពាល់នៃការជ្រៀតជ្រែកផ្នែកនយោបាយនៅអង្គជំនុំជម្រះមួយនេះ គឺមានភាពច្បាស់លាស់ក្នុងពេលឥឡូវនេះ។ ការិយាល័យកិច្ចការសាធារណៈនៃ អ.វ.ត.ក ព្យាយាមពន្យល់ពីភាពអសកម្មរបស់ ស.ច.ស ជាការប្រុងប្រយ័ត្នចាំបាច់ ដើម្បីជៀសវាង៖

“ការបង្កើតនូវក្តីសង្ឃឹមដែលមិនពិតប្រាកដមួយ ទៅឱ្យជនរងគ្រោះ ដែលពួកគាត់មានបំណងចង់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីក្លាយខ្លួនទៅជាដើមបណ្តឹងរដ្ឋប្បវេណី” តាម “បទពិសោធន៍សំណុំរឿង00២” បង្ហាញឱ្យឃើញថា “វាជាហានិភ័យមួយដែលថាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើន ដែលបានដាក់រួច [ក្នុងសំណុំរឿង00៣] អាចស្ថិតនៅក្រៅវិសាលភាពនៃកិច្ចស៊ើបសួរ[១០៦]”។

១០៥. ការពន្យល់នេះមិនបានគិតដល់ដំណោះស្រាយដ៏ងាយស្រួលមួយ គឺ ស.ច.ស អាចផ្សព្វផ្សាយព័ត៌មាន*មួយចំនួន*អំពីវិសាលភាពនៃកិច្ចស៊ើបសួរ។ ក៏ប៉ុន្តែ ការពន្យល់ដែលចុះផ្សាយនៅលើគេហទំព័រ អ.វ.ត.ក គឺជាការជួយលុបលាងនូវកិច្ចខិតខំប្រឹងប្រែងរបស់ ស.ច.ស ក្នុងការរារាំងមិនឱ្យមានការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង00៣។

១០៦. ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក៏ដូចជាភាពអសកម្មជាបន្តបន្ទាប់ទាក់ទិនទៅនឹងសំណើរសុំឱ្យស៊ើបអង្កេតបន្ថែមរបស់សហព្រះរាជ

---

[១០៥] Julia Wallace “ការស៊ើបអង្កេតក្នុងសំណុំរឿង00៣ឈានដល់ទីបញ្ចប់” *The Cambodia Daily* ចុះផ្សាយថ្ងៃទី ២០ ខែ មេសា - ថ្ងៃទី១ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រទី២។

[១០៦] សូមមើលគេហទំព័រជាផ្លូវការរបស់អ.វ.ត.ក http://www.eccc.gov.kh/en/articles/frequently-asked-questions-about-case-003 មើលនៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១១។

អាជ្ញាអន្តរជាតិនោះ[១០៧] ជាការបង្ហាញថា ស.ច.ស កំពុងបំពេញការងារផ្ទុយទៅនឹងបេសកកម្មរបស់ អ.វ.ត.ក ហើយបានបង្កើតជាករណីយុត្តិសាស្ត្រដ៏គ្រោះថ្នាក់មួយស្តីពីនិទណ្ឌភាពសម្រាប់បុគ្គលទាំងឡាយណាដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មជាទ្រង់ទ្រាយធំ។

១០៧. លោក James A. Goldston នៃអង្គការ OSJI បានថ្លែងនៅក្នុងសេចក្តីថ្លែងការណ៍សាព័ត៌មានមួយ កាលពីថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១១ ថា៖

> ការបន្តមិនយកចិត្តទុកដាក់លើការចោទប្រកាន់ទាំងនេះ គឺគ្រាន់តែជួយបន្ថែមហានិយភ័យដល់ការស្វែងរកយុត្តិធម៌នៅក្នុងប្រទេសកម្ពុជាជាកេរ្តិ៍ដំណែលរបស់ អ.វ.ត.ក និងធ្វើឱ្យប៉ះពាល់ដល់ការរួមចំណែកដោយផ្ទាល់របស់អង្គការសហប្រជាជាតិ ចំពោះការអភិវឌ្ឍច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[១០៨]។

ប្រសិនបើសំណុំរឿង០០៣ ត្រូវបានលើកលែងចោល ដោយសារតែមានការជ្រៀតជ្រែកផ្នែកនយោបាយ និងដោយគ្មានតម្លាភាព ឬការត្រួតពិនិត្យនោះ ការខូចខាតដ៏សំខាន់នឹងកើតមានចំពោះធម្មនុញ្ញរូបទាំងស្រុងរបស់អង្គជំនុំជម្រះ និងចំពោះការបន្តប្រយុទ្ធប្រឆាំងជាមួយនិទណ្ឌភាព។

១០៨. សរុបសេចក្តីទៅ ស.ច.ស កំពុងតែរារាំងដំណើរការស្វែងរកយុត្តិធម៌របស់ អ.វ.ត.ក ហើយកំពុងធ្វើឱ្យនិទណ្ឌភាពឈ្នះលើសអ្វីទាំងអស់ ហើយដីកាសម្រេចបដិសេធមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted] នៅក្នុងសំណុំរឿង ០០៣ គឺជាឧទាហរណ៍មួយទៀតដែលបង្ហាញពីកម្រិតនៃការជ្រៀតជ្រែកផ្នែកនយោបាយដែលមាននៅតុលាការ អ.វ.ត.កនេះ។

---

[១០៧] អនុវត្តតាមសេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាជាតិ "សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងសំណុំរឿង០០៣" ចេញថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១១ មានការបង្ហាញយ៉ាងច្បាស់ថា រាល់សំណើសុំឱ្យមានការស៊ើបអង្កេតបន្ថែមនឹងត្រូវចេញពីសហព្រះរាជអាជ្ញាអន្តរជាតិប៉ុណ្ណោះ។ ក្នុងសេចក្តីថ្លែងការណ៍នេះ សហព្រះរាជអាជ្ញាជាតិ លោកស្រី ជា លាង "ប្រកាន់ជំហរថា ជនសង្ស័យ ដែលមានឈ្មោះនៅក្នុងសំណុំរឿងលេខ០០៣ មិនស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែលត្រូវយកមកធ្វើការកាត់សេចក្តីឡើយ ហើយការកាត់សេចក្តីទៅលើជនជាប់ចោទដែលកំពុងតែជាប់ឃុំនៅ អ.វ.ត.ក គឺជាការបំពេញបានយ៉ាងគ្រប់គ្រាន់ចំពោះអាណត្តិរបស់តុលាការនេះ"។

[១០៨] សេចក្តីប្រកាសព័ត៌មានរបស់ OSJI "តុលាការខ្មែរក្រហមរបស់កម្ពុជាផាត់ចោលសំឡេងរបស់ជនរងគ្រោះ" *អាចរកមើលបាននៅ៖* http://www.soros.org/initiatives/justice/news/cambodia-victims-20110916

១០៩. ជាមួយនឹងរាល់សំអាងហេតុផ្នែកផ្លូវច្បាប់ដែលបានដកស្រង់ក្នុងបណ្តឹងឧទ្ធរណ៍នេះ ដែលផ្អែកលើការបកស្រាយដ៏ត្រឹមត្រូវតាមផ្លូវច្បាប់ ព្រមទាំងការអនុវត្តច្បាប់ដោយសមស្របចំពោះអង្គហេតុដែលទាក់ទងនឹងបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍នេះ [redacted] ត្រូវតែបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿង ០០៣។

១១០. ម្ចាស់បណ្តឹងឧទ្ធរណ៍ រំពឹងថា នីតិវិធីដ៏ត្រឹមត្រូវនេះ ក៏នឹងត្រូវអនុវត្តផងដែរចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍នៅក្នុងសំណុំរឿង ០០៥។

## VII. សេចក្តីសន្និដ្ឋាន និងសំណូមពរ

១១១. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើដោយក្តីគោរពដល់អង្គបុរេជំនុំជម្រះមេត្តា៖

- i. ប្រកាសថាបណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន និង
- ii. ច្រានចោលនូវសេចក្តីសម្រេចនៅក្នុងដីការបស់សហចៅក្រមស៊ើបអង្កេតដែលសម្រេចបដិសេធមិនទទួលយកម្ចាស់បណ្តឹងឧទ្ធរណ៍ជាដើមបណ្តឹងរដ្ឋប្បវេណី និង
- iii. ពិចារណាទៅលើរាល់សារណាផ្លូវច្បាប់ និងសេចក្តីថ្លែងការណ៍ទាំងអស់ដែលបានធ្វើឡើង និង
- iv. ផ្តល់ឋានៈដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ ជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿង ០០៣ ព្រមទាំង
- v. ផ្តល់សិទ្ធិឱ្យមេធាវីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍អាចមើលសំណុំរឿង០០៣បាន។

សូមដាក់ជូនបណ្តឹងឧទ្ធរណ៍នេះដោយសេចក្តីគោរពពី៖

០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

លោក សំ សុគង់ លោកស្រី Lyma NGUYEN

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

បានចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា និងរដ្ឋធានី Darwin ប្រទេសអូស្ត្រាលី នៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១។